# ការសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែង និងភាពប្រឈមនានា ចំពោះសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ នៅក្នុងប្រទេសកម្ពុជា




របាយការណ៍នេះរៀបចំដោយៈ ក្រុមការងារនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ៖ លោក អេង ប៉ូឡូ លោក ស៊ុយ សុធារ៉ា លោក សេម វីដា លោកស្រី ស៊ឹម ឆវី និង កញ្ញា នន ណារីន

សហការ និងគាំទ្រដោយអង្គការ RECOFTC តាមរយៈ គម្រោង CF-FLEGT

FAO FLEGT PROGRAMME

Food and Agriculture Organization of the United Nations

SWEDEN

UKaid from the British people

RECOFTC
THE CENTER FOR PEOPLE AND FORESTS

ការសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែង និងភាពប្រឈមនានា ចំពោះសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា

© រក្សាសិទ្ធដោយ RECOFTC  ឆ្នាំ ២០១៦

រាល់រូបភាពដែលប្រើប្រាស់ក្នុងរបាយការណ៍នេះជាកម្មសិទ្ធិរបស់អង្គការ RECOFTC និង វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

ការបោះពុម្ព និងការផលិតឯកសារនេះឡើងវិញ សម្រាប់ការអប់រំ និងគោលបំណងទាំងឡាយណាដែលមិនសំដៅរកប្រាក់ចំណេញ អាចធ្វើបានដោយមិនចាំបាច់សុំការអនុញ្ញាតិជាលាយល័ក្ខអក្សរ ពីម្ចាស់កម្មសិទ្ធិជាមុនឡើយ តែអ្នកប្រើប្រាស់ត្រូវបញ្ជាក់ពីប្រភព ឯកសារនិងអ្នករៀបរៀងឲ្យបានច្បាស់ ។ រាល់ការបោះពុម្ព ឯកសារនេះ ឡើងវិញសម្រាប់គោលបំណងលក់ដូរ និងប្រាក់ចំណេញមិនត្រូវបាន អនុញ្ញាតិឡើយ លើកលែងតែមានការព្រមព្រៀងជាមុនជាលាយល័ក្ខអក្សរពីម្ចាស់ កម្មសិទ្ធិ។

របាយការណ៍នៃការវាយតម្លៃនេះ បានរៀបចំដោយមានការគាំទ្រពីសហភាពអឺរ៉ុប (EU) និងអង្គការស្បៀង  និងកសិកម្មនៃសហប្រជាជាតិ (FAO)  ។  រាល់ខ្លឹមសារក្នុងរបាយការណ៍នេះ  ជាទំនួលខុសត្រូវទាំងស្រុងរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើដោយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ EU រឺ FAO  និងអង្គការ RECOFTC ឡើយ ។

# ការសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែង និងភាពប្រឈមនានា ចំពោះសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា

អង្គការ RECOFTC
រាជធានីភ្នំពេញ

# មាតិកា


បញ្ជីអក្សរកាត់....................iii

១. សេចក្តីផ្តើម....................1

២. គោលបំណងនៃការវាយតម្លៃ ....................2

៣. សាវតាគម្រោង....................2

៤. វិធីសាស្ត្រនៃការវាយតម្លៃ....................3

៤.១.ឧបករណ៍ និងដំណើរការនៃការវាយតម្លៃ....................3

៤.១.១. ចំនួនសំណាកសម្រាប់ការវាយតម្លៃ ....................3

៤.១.២. សិក្សាលើឯកសារដែលមានស្រាប់ (Desk review).................... 4

៤.១.៣. ការប្រមូលទិន្នន័យនៅទីវាល....................4

៤.២. ការវិភាគទិន្នន័យ....................4

៤.៣. វិសាលភាព និងដែនកំណត់....................4

៥. លទ្ធផលនៃការសិក្សាវាយតម្លៃ....................8

៥.១.តួនាទីសមាជិកសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ....................8

៥.១.១.អភិបាលកិច្ច....................8

៥.១.២.ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ....................10

៥.១.៣.ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ....................12

៥.២. តួនាទីអាជ្ញាធរមូលដ្ឋាន....................12

៥.២.១.អភិបាលកិច្ច....................12

៥.២.២.ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ....................13

៥.២.៣.ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ....................13

៥.៣. តួនាទីរបស់រដ្ឋបាលព្រៃឈើ....................14

៥.៣.១.អភិបាលកិច្ច....................14

៥.៣.២.ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ....................16

៥.៣.៣.ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ....................16

៦. ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍....................18

៦.១. ការសន្និដ្ឋាន....................18

៦.២. ការផ្តល់អនុសាសន៍....................19

៦.២.១. អភិបាលកិច្ច....................19

៦.២.២ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ....................20

៦.២.៣. ពាណិជ្ជកម្មសហគមន៍ព្រៃឈើ....................21

ឯកសារយោង....................22

# តារាងឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១. តារាងពេលវេលានៃការវាយតម្លៃ....24
ឧបសម្ព័ន្ធទី ២. តារាងលទ្ធផលនៃវាយតម្លៃនៅខេត្តក្រចេះ....26
ឧបសម្ព័ន្ធទី ៣. តារាងលទ្ធផលនៃវាយតម្លៃនៅខេត្តកំពង់ស្ពឺ....29
ឧបសម្ព័ន្ធទី ៤. តារាងលទ្ធផលនៃវាយតម្លៃនៅខេត្តកំពង់ធំ....32
ឧបសម្ពន្ធ័ទី ៥. បញ្ជីសំណួរ....35
ឧបសម្ព័ន្ធទី ៦. ការណែនាំអំពីការវាយតម្លៃ....38


# បញ្ជីរូបភាព


រូបទី ១. រូបមន្តប្រើប្រាស់ក្នុងការកំណត់សំណាក....3
រូបទី ២. ដំណើរការនៃការប្រមូលទិន្នន័យ....5
រូបទី ៣. ទីតាំងនៃការសិក្សា....6
រូបទី ៤. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ....26
រូបទី ៥. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ស្ពឺ....29
រូបទី ៦. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ធំ....32


# បញ្ជីតារាង


តារាងទី ១. ចំនួនសំណាកដែលបានជ្រើសរើសសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ព្រៃឈើតាមបណ្តាខេត្តគោលដៅ....3
តារាងទី ២. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនខេត្តក្រចេះដី....27
តារាងទី ៣. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដីខេត្តកំពង់ស្ពឺ....30
តារាងទី ៤. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដីខេត្តកំពង់ធំ....33

# បញ្ជីអក្សរកាត់

| | |
|---|---|
| CF | សហគមន៍ព្រៃឈើ<br>Community Forestry |
| CFDF | មូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើ<br>Community Forestry Development Funds |
| CF-FLEGT | ពង្រឹងតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ<br>Community Forestry – Forest Law Enforcement, Governance and Trade |
| CFMC | គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ<br>Community Forestry Management Committee |
| CFMP | ផែនការគ្រប់គ្រងព្រៃសហគមន៍<br>Community Forestry Management Plan |
| FA | រដ្ឋបាលព្រៃឈើ<br>Forestry Administration |
| FLEGT | ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើ<br>Forest Law Enforcement, Governance and Trade |
| IRD | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ<br>Institute of Forest and Wildlife Research and Development |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>Ministry of Agriculture, Forestry and Fisheries |
| NGO | អង្គការមិនមែនរដ្ឋាភិបាល<br>Non-Governmental Organization |
| NTFP | អនុផលព្រៃឈើ<br>Non-Timber Forest Products |
| RECOFTC | មជ្ឈមណ្ឌលបណ្ដុះបណ្ដាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (រីមជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ)<br>Regional Community Forestry Training Center for Asia and the Pacific (also known as The Center for People and Forests) |
| SFM | ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព<br>Sustainable Forest Management |
| UNDP-GEF | កម្មវិធីអភិវឌ្ឍសហប្រជាជាតិ - មូលនិធិបរិស្ថានសកល<br>United Nation Development Programme – Global Environment Facility |

# ១. សេចក្តីផ្តើម

កម្មវិធីព្រៃឈើជាតិ (NFP) បានរៀបរៀងឡើងដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ ២០១០ ដោយបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលវែង (២០១០-២០២៩) សម្រាប់ការគ្រប់គ្រងធនធានព្រៃឈើក្នុងប្រទេសប្រកបដោយនិរន្តរភាព ។ កម្មវិធីព្រៃឈើជាតិមានកម្មវិធីអាទិភាពចំនួន ៦ ដែលក្នុងនោះ កម្មវិធីចំនួន ២ ពាក់ព័ន្ធ និងផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាសហគមន៍គឺ កម្មវិធីទី ៣ និងកម្មវិធីទី ៤ ។ កម្មវិធីទី ៣ ស្តីពីការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ដែលមានគោលបំណងរួមដើម្បីពង្រឹង ការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច នឹងចូលរួមចំណែកក្នុងការគ្រប់គ្រង ការពារ និងអភិវឌ្ឍព្រៃឈើប្រកបដោយតម្លាភាព ត្រឹមត្រូវ និងមានប្រសិទ្ធភាព ។ កម្មវិធីទី ៤ ស្តីពីសហគមន៍ព្រៃឈើ ដោយបានដាក់ចេញនូវគោលដៅនៃការបង្កើតសហគមន៍ព្រៃឈើ ឲ្យបាន ២ លានហិកតា (ប្រមាណជា ១.០០០ កន្លែង នៅត្រឹមឆ្នាំ ២០២៩) ។ យោងតាមស្ថិតិចុងក្រោយរបស់រដ្ឋបាលព្រៃឈើដែលបានបោះពុម្ពផ្សាយនៅខែកញ្ញា ឆ្នាំ ២០១៥ មកដល់ពេលនេះមានសហគមន៍ព្រៃឈើចំនួន ៤៩៩ កន្លែងត្រូវបានបង្កើតឡើងដែលគ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ៤១៧.៦៣៥ ហិកតា និងមានការចូលរួមពីប្រជាជនមូលដ្ឋានចំនួន ១២០.០៨០ គ្រួសារ ។ បណ្តាញសហគមន៍ព្រៃឈើនៅក្នុងខេត្តចំនួន ៩ ត្រូវបានបង្កើតឡើងផងដែរ ដើម្បីពង្រឹង កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលសកម្មភាពសហគមន៍ព្រៃឈើ និងការពង្រឹងតួនាទីសហគមន៍ព្រៃឈើ ក្នុងការសម្រេចចិត្តជាគោលនយោបាយ ដើម្បីការពារផលប្រយោជន៍សមាជិកសហគមន៍ព្រៃឈើទាំងអស់ ។ ការបង្កើតបណ្តាញសហគមន៍ព្រៃឈើនេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងកំណើននៃចំនួនសហគមន៍ព្រៃឈើនៅក្នុងប្រទេស ។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើ ជាផ្នែកមួយដ៏ចំបាច់ ដែលគាំទ្រដល់ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព តម្លាភាព និងពង្រឹងនូវភាពជាម្ចាស់លើការគ្រប់គ្រងសហគមន៍ព្រៃឈើ របស់សមាជិកសហគមន៍ព្រៃឈើ ។ មិនតែប៉ុណ្ណោះ ការចូលរួមរបស់សហគមន៍មូលដ្ឋាននៅក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ បានជួយលើកស្ទួយកំរិតជីវភាពរបស់ពួកគេឲ្យកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់អនុផលព្រៃឈើនៅក្នុងគោលបំណងពាណិជ្ជកម្ម ។ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ របស់រាជរដ្ឋាភិបាល គម្រោង "ពង្រឹងតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ (CF-FLEGT)" ត្រូវបានបង្កើតឡើងដែល អនុវត្តដោយអង្គការ RECOFTC សហការជាមួយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃនៃរដ្ឋបាលព្រៃឈើ ក្រោមជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប (EU) និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) តាមរយៈកម្មវិធី EU FAO FLEGT ដោយគាំទ្រ ទៅលើការអនុវត្តសាកល្បងក្នុងសហគមន៍ព្រៃឈើចំនួន ៤ ក្នុងខេត្តកំពង់ស្ពឺ ដោយផ្តោតទៅលើការប្រមូលផល និងការធ្វើជំនួញឫស្សី ។

នៅក្នុងគម្រោងនេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ បានធ្វើការសិក្សាវាយតម្លៃទៅលើចំណុចខ្លាំង និងចំណុចខ្សោយ នៃអភិបាលកិច្ចព្រៃឈើនៅក្នុងការពង្រឹងការអនុវត្តច្បាប់ ពីសំណាក់សហគមន៍ និងរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីស្វែងយល់អំពីហានិភ័យ និងឱកាសសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងការលើកស្ទួយ របរចិញ្ចឹមជីវិតតាមរយៈ ជំនួញផល-អនុផលព្រៃឈើ ។ ការសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែង និងភាពប្រឈម នានាចំពោះសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ធ្វើឡើងនៅក្នុងខេត្តចំនួន ៣ គឺខេត្តក្រចេះ ខេត្ត

កំពង់ស្ពឺ និងខេត្តកំពង់ធំ ដែលខេត្តនីមួយៗតំណាងអោយអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប និងអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ ។

## ២. គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃនេះគឺដើម្បីស្វែងយល់ពីសមត្ថភាពរបស់សហគមន៍ ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ក្នុងក្របខ័ណ្ឌសហគមន៍ព្រៃឈើស្របតាមកម្មវិធីព្រៃឈើជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការវាយតម្លៃនេះផ្តោតទៅលើ៖

- ចំណុចខ្លាំង និងចំណុចខ្សោយ នៃអភិបាលកិច្ចព្រៃឈើ ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ របស់សហគមន៍ មន្ត្រីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន
- ហានិភ័យ និងឱកាសសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងការលើកស្ទួយរបរចិញ្ចឹមជីវិតតាមរយៈការធ្វើជំនួញផល-អនុផលព្រៃឈើ។

## ៣. សាវតាគម្រោង

គម្រោង "ពង្រឹងតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ" (CF-FLEGT) អនុវត្តដោយអង្គការ RECOFTC សហការជាមួយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ ក្រោមជំនួយហិរញ្ញវត្ថុពីកម្មវិធី EU FAO FLEGT ។ គម្រោងនេះមានគោលបំណងពង្រឹងតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ស្របតាមកម្មវិធីព្រៃឈើជាតិ ។ គម្រោងចាប់អនុវត្តពី ខែមេសា ឆ្នាំ ២០១៥ ដល់ខែកញ្ញា ឆ្នាំ ២០១៦ ដោយមានលទ្ធផលរំពឹងទុកដូចខាងក្រោមនេះ៖

**លទ្ធផលទី ១ ៖** ស្ថានភាពជាក់ស្តែង និងភាពប្រឈមនានា ចំពោះសហគមន៍ព្រៃឈើ ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ នៅក្នុងប្រទេសកម្ពុជាត្រូវបានធ្វើការវាយតម្លៃ

**លទ្ធផលទី ២ ៖** ប្រមូល និងចងក្រងនូវបទពិសោធន៍នៃគម្រោង "ពង្រឹងតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ" នៅក្នុងខេត្តកំពង់ស្ពឺ

**លទ្ធផលទី ៣ ៖** តាមរយៈការអនុវត្តសាកល្បងគម្រោងនេះ និងការពិភាក្សាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ក្នុងក្របខណ្ឌប្រតិបត្តិ នឹងផ្តល់ជាអនុសាសន៍ក្នុងការរួមចំណែកដល់ការកែសម្រួល ប្រកាសស្តីពីគោលការណ៍អំពីសហគមន៍ព្រៃឈើឲ្យកាន់តែមានភាពប្រសើរឡើង ។

**លទ្ធផលទី ៤ ៖** រៀបចំក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសំភារៈផ្សព្វផ្សាយ។

# ៤. វិធីសាស្ត្រនៃការវាយតម្លៃ

## ៤.១. ឧបករណ៍ និងដំណើរការនៃការវាយតម្លៃ

ការសិក្សាវាយតម្លៃនេះបានធ្វើឡើងដោយក្រុមការងារដែលមានសមាជិកចំនួន ៥ រូបមកពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ និងមានរយៈពេលពី ៥ ទៅ ៦ ថ្ងៃ នៅក្នុងខេត្តគោលដៅនីមួយៗ ។ ការសិក្សានេះ ក៏បានប្រើប្រាស់នូវប្រភពទិន្នន័យដែលមានស្រាប់ នៅក្នុងខេត្តគោលដៅនីមួយៗផងដែរ ។ រូបទី ២ បង្ហាញពីដំណើរការនៃការប្រមូលទិន្នន័យទាំងអស់។

### ៤.១.១. ចំនួនសំណាកសម្រាប់ការវាយតម្លៃ

ការសិក្សានេះបានប្រើប្រាស់រូបមន្តរបស់ Yamane ឆ្នាំ ១៩៧៦ (សូមមើល រូបទី ១ ខាងក្រោម) ដើម្បីកំណត់ចំនួនសំណាកសហគមន៍ព្រៃឈើនៅក្នុងខេត្តគោលដៅនីមួយៗ ។

រូបទី ១. រូបមន្តប្រើប្រាស់ក្នុងការកំណត់សំណាក

$$n = \frac{N}{1+Ne^2}$$

N: ចំនួនសហគមន៍ក្នុងតំបន់សិក្សា

e: កំរិតលំអៀង ២៥%

n: ចំនួនសំណាកដែលត្រូវជ្រើសរើស

តារាងទី ១. ចំនួនសំណាកដែលបានជ្រើសរើសសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ព្រៃឈើតាមបណ្តាខេត្តគោលដៅ

| ល.រ | ខេត្ត | ចំនួនសហគមន៍ព្រៃឈើដែលមានកិច្ចព្រមព្រៀង | សំនួនសំណាក |
|---|---|---|---|
| ១ | ខេត្តក្រចេះ | ២៧ | n= ២៧/(១+២៧*0,២៥*0,២៥) = ១0 សហគមន៍ (ប៉ុន្តែមានសហគមន៍ព្រៃឈើចំនួន ៥ តែប៉ុណ្ណោះដែលបានលើកយកមកសិក្សា ដោយសារសហគមន៍ដទៃទៀតពិបាកក្នុងការធ្វើដំណើរទៅដល់ និងពេលវេលាមិនគ្រប់គ្រាន់) |
| ២ | ខេត្តកំពង់ស្ពឺ | ១៨ | n= ១៨/(១+១៨*0,២៥*0,២៥) = 0៨ សហគមន៍ |
| ៣ | ខេត្តកំពង់ធំ | ៦៧ | n= ៦៧/(១+៦៧*0,២៥*0,២៥) = ១២ សហគមន៍ |

### ៤.១.២. សិក្សាលើឯកសារដែលមានស្រាប់

ទិន្នន័យដែលមានស្រាប់ពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើនៅក្នុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តក្រចេះ ត្រូវបានប្រមូលទុកជាមុន និងក្នុងកំឡុងពេលសិក្សា ដើម្បីបំពេញបន្ថែមចំពោះទិន្នន័យប្រមូលពីទីវាល រួមមាន ៖ ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ (លេខ ៧៩ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០០៣) គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើឆ្នាំ ២០០៦ កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩ ស្ថិតិសហគមន៍ព្រៃឈើកម្ពុជាឆ្នាំ ២០១៥ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ក្នុងសហគមន៍គោលដៅដែលបានជ្រើសរើស ។

### ៤.១.៣. ការប្រមូលទិន្នន័យនៅទីវាល

ទិន្នន័យនៅទីវាលត្រូវបានប្រមូលក្នុងកំឡុង ខែវិច្ឆិកា ឆ្នាំ ២០១៥ តាមរយៈការប្រជុំពិភាក្សាជាក្រុម និងដាច់ដោយឡែក តាមបណ្តាសហគមន៍ព្រៃឈើដែលបានជ្រើសរើស ដោយប្រើប្រាស់រូបមន្តសម្រាប់ការវាយតម្លៃ (តារាងទី ១ ខាងលើ) ជាមួយគណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ អាជ្ញាធរឃុំ រដ្ឋបាលព្រៃឈើមូលដ្ឋាន អង្គការពាក់ព័ន្ធ និងបណ្តាញសហគមន៍ព្រៃឈើ ។

## ៤.២. ការវិភាគទិន្នន័យ

ទិន្នន័យទាំងអស់ដែលបានមកពីកិច្ចប្រជុំពិគ្រោះយោបល់ ត្រូវបានបញ្ចូលទៅក្នុង ឧបសម្ព័ន្ធទី ២ ហើយយកមកវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ នៃតួនាទីរបស់គណៈកម្មាការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ អាជ្ញាធរឃុំ រដ្ឋបាលព្រៃឈើមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនានា នៅក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ។

## ៤.៣. វិសាលភាព និងដែនកំណត់

ដោយសារថវិកាមានចំនួនកំណត់ និងពេលវេលាចុះសិក្សាមានរយៈពេលតែ ៥ ទៅ ៦ ថ្ងៃសម្រាប់តំបន់គោលដៅក្នុងខេត្តនីមួយៗ ដូច្នេះការសិក្សានេះផ្តោតសំខាន់តែលើសហគមន៍ព្រៃឈើទាំងឡាយណាដែលមានកិច្ចព្រមព្រៀង និងមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅដល់តាមផ្លូវគោក ក្នុងបណ្តាខេត្តនីមួយៗ (សូមមើល តារាងទី ១) ។

រូបទី ២. ដំណើរការនៃការប្រមូលទិន្នន័យ



រូបទី ៣. ទីតាំងនៃការសិក្សា





# ៥. លទ្ធផលនៃការសិក្សាវាយតម្លៃ

លទ្ធផលនៃការសិក្សានេះត្រូវបានបង្ហាញទៅតាមផ្នែកនីមួយៗចំពោះក្រុមអ្នកពាក់ព័ន្ធផ្សេងៗ (គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើមូលដ្ឋាន) ទៅតាមប្រធានបទសំខាន់ៗ ចំនួន ៣គឺៈ

- អភិបាលកិច្ចព្រៃឈើ៖ គឺសំដៅលើសមត្ថភាពក្នុងការគ្រប់គ្រង ការពារ និងអភិវឌ្ឍព្រៃឈើប្រកបដោយតម្លាភាព គណនេយ្យភាព ការទទួលខុសត្រូវ និងមានប្រសិទ្ធភាព (ឧទាហរណ៍៖ ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព គណនេយ្យភាព ការចូលរួមពីអ្នកពាក់ព័ន្ធ និងវិធានការពង្រឹងការអនុវត្តច្បាប់)។ សម្រាប់បរិបទសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជា គឺផ្តោតការយកចិត្តទុកដាក់របស់សមាជិក សហគមន៍ព្រៃឈើ និងអ្នកពាក់ព័ន្ធ ទៅលើសកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើអោយមាន តម្លាភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគណនេយ្យភាព ។
- ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ៖ គឺសំដៅទៅលើការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ។ សម្រាប់បរិបទសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជា គឺផ្តោតទៅលើប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការគាំទ្រដល់ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។
- ពាណិជ្ជកម្មឈើ៖ គឺសំដៅទៅលើជំនួញផល-អនុផលព្រៃឈើ។សម្រាប់បរិបទសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជាគឺផ្តោតទៅលើនីតិវិធីសម្រាប់សមាជិកសហគមន៍ព្រៃឈើក្នុងការទទួលបានការអនុញ្ញាតិ្តដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារក្នុងស្រុក ។

## ៥.១. តួនាទីសមាជិកសហគមន៍ព្រៃឈើ ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើផលិតសហគមន៍ព្រៃឈើ

### ៥.១.១. អភិបាលកិច្ច

*ការចូលរួម*

ក្នុងចំណោមសហគមន៍ព្រៃឈើដែល ត្រូវបានធ្វើការសំភាសន៍ បានបង្ហាញថាសមាជិកសហគមន៍ព្រៃឈើលើសពី ៦៥% បានចូលរួមនៅក្នុងការដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើ ពួកគេមើលឃើញពីសក្តានុពល និងគុណតម្លៃរបស់សហគមន៍ព្រៃឈើ ក្នុងការលើកស្ទួយការទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់ពួកគេ ។ លើសពីនេះទៀត សហគមន៍មូលដ្ឋានមើលឃើញថាការបង្កើតសហគមន៍ព្រៃឈើ គឺជាយន្តការមួយក្នុងការការពារ និងទទួលបានសិទ្ធិស្របច្បាប់ លើការគ្រប់គ្រងដីព្រៃដែលពួកគេពឹងអាស្រ័យ ជាពិសេសទប់ស្កាត់ចរន្តសម្បទានដីសេដ្ឋកិច្ចដែលបានរីកដុះដាល នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ។ សហគមន៍ក៏បានពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការគ្រប់គ្រងព្រៃឈើ តាមរយៈសកម្មភាពផ្សេងៗ រួមមានកិច្ចប្រជុំផ្សព្វផ្សាយពីសារៈសំខាន់សហគមន៍ព្រៃឈើ ហើយសមាជិកសហគមន៍ព្រៃឈើជាច្រើន បានចូលរួមនៅក្នុងសកម្មភាព និងដំណើរការរៀបចំសហគមន៍ព្រៃឈើដូចជា ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើ ការកំណត់តំបន់សក្តានុពល



ព្រៃសហគមន៍ ការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ បទបញ្ជាផ្ទៃរបស់គណៈកម្មការគ្រប់គ្រងព្រៃឈើ ការចុះល្បាត ព្រមទាំងការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងការអនុវត្ត ។ សហគមន៍ព្រៃឈើនៅក្នុងខេត្តក្រចេះ និងខេត្តកំពង់ធំ ក៏បានចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍រវាងគ្នាទៅវិញទៅមក ព្រមទាំងបានលើកឡើងនូវបញ្ហាប្រឈមនានា ដែលកើតនៅឡើងក្នុងសហគមន៍តាមរយៈបណ្តាញសហគមន៍ព្រៃឈើ ដែលបានបង្កើតចាប់ពីថ្នាក់ឃុំ ដល់ថ្នាក់ខេត្ត ។

ជារួមមកមានសមាជិកសហគមន៍ព្រៃឈើជាច្រើនបានចូលរួមក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ តែទោះជាយ៉ាង នេះក្តី គេសង្កេតឃើញមានការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមានកម្រិតនៅឡើយ ជាពិសេសសំរាប់ សមាជិកសហគមន៍ជាស្ត្រី ដោយសារលទ្ធភាពរបស់ពួកគេនៅមានកម្រិត ។ ការសិក្សានេះកំណត់បាននូវបញ្ហាមួយចំនួនដែលជាឧបសគ្គរារាំងដល់ស្ត្រីក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តដូចជា៖

- ស្ត្រីនៅមានការខ្មាស់អៀនច្រើនក្នុងការបញ្ចេញមតិ នៅក្នុងក្រុមដែលមានបុរសចូលរួម
- ស្ត្រីច្រើនតែធ្វើការសម្រេចចិត្តតាមបុរស
- តំណាងដែលជាស្ត្រីនៅក្នុងជួរគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនៅមានចំនួនតិចទៅឡើយ
- ចំណេះដឹងរបស់ស្ត្រីទាក់ទងទៅនឹងច្បាប់ស្តីអំពីព្រៃឈើ និងបទដ្ឋានទាក់ទងនានានៅមានកម្រិតទាបនៅឡើយ (ជាពិសេសបើប្រៀបធៀបជាមួយចំនួនបុរស)

ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ គេចាំបាច់ត្រូវពិនិត្យមើលឡើងវិញនូវលក្ខន្តិកៈសហគមន៍ព្រៃឈើ ដើម្បីរកលទ្ធភាពក្នុងការបង្កើនចំនួន និងការចូលរួមរបស់ស្ត្រីឲ្យបានពេញលេញក្នុងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ការកសាងសមត្ថភាពសម្រាប់ស្ត្រីពីសំណាក់ស្ថាប័នជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលនានា ក៏ជាកត្តាចំបាច់ ដើម្បីលើកកម្ពស់ការបំពេញការងាររបស់ពួកគេ ក្នុងការគាំទ្រដល់សកម្មភាពអភិវឌ្ឍ

សហគមន៍ព្រៃឈើ ដោយផ្តោតទៅលើ៖

- ការវាយតម្លៃទៅលើតម្រូវការរបស់ស្ត្រីពាក់ព័ន្ធទៅនឹងបរិបទនៃការអភិវឌ្ឍសហគមន៍ព្រៃឈើ
- ការវាយតម្លៃទៅលើតម្រូវការរបស់ស្ត្រីចំពោះតួនាទី និងភារកិច្ចរបស់ពួកគេនៅក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីពង្រឹងសមត្ថភាពស្ត្រី តាមរយៈការបណ្តុះបណ្តាល និងការសិក្សារៀនសូត្រច្បាប់ស្តីពីព្រៃឈើ និងបទដ្ឋានគតិយុទ្ធទាក់ទងនឹងតួនាទីរបស់ស្ត្រី ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ និងតួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងព្រៃឈើស្របតាមបរិបទបណ្តាញសហគមន៍ព្រៃឈើ ។

*តម្លាភាព*

រាល់គម្រោងផែនការអភិវឌ្ឍសហគមន៍ព្រៃឈើ ត្រូវបានឆ្លងកាត់ការពិគ្រោះយោបល់ និងមានការឯកភាពពីសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធនានាមុននឹងដាក់ឲ្យអនុវត្ត ។ រដ្ឋបាលព្រៃឈើមូលដ្ឋាន និងតំណាងអង្គការមិនមែនរដ្ឋាភិបាលនានា បានពិនិត្យមើល និងតាមដានលើដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើ ការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ ការរៀបចំគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការរៀបចំផែនការជំនួញ ។ កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានរៀបចំឡើងជាប្រចាំ និងកិច្ចប្រជុំសហគមន៍ព្រៃឈើប្រចាំឆ្នាំក៏ត្រូវបានរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលនៃការដោះស្រាយបញ្ហាសំខាន់ៗ និងដើម្បីរៀបចំសកម្មភាពសម្រាប់ការអភិវឌ្ឍសហគមន៍ព្រៃឈើ ។

ចំពោះសហគមន៍ព្រៃឈើទាំងឡាយណាដែលមានមូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ បានចាត់តាំងសមាជិក ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិនេះ និងរាយការណ៍ជាប្រចាំ អំពីវឌ្ឍនភាពជូនដល់គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើទាំងអស់ ។ តែទោះជាយ៉ាងនេះក៏ដោយ ដើម្បីធានាថា ការអនុវត្តប្រកបដោយតម្លាភាព ចាំបាច់ត្រូវមានការត្រួតពិនិត្យជាប្រចាំពីស្ថាប័នជំនាញរដ្ឋបាលព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផងដែរ។

## ៥.១.២. ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ ក្នុងដែនព្រៃសហគមន៍ បន្ទាប់ពីសហគមន៍របស់ពួកគេបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយខណ្ឌរដ្ឋបាលព្រៃឈើសាមី ។ សកម្មភាពទាក់ទងនឹងការចុះល្បាត ត្រូវបានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ ហើយការចុះល្បាតត្រូវបានអនុវត្តជាប្រចាំ ។ របាយការណ៍ស្តីពីការចុះល្បាតត្រូវ បានផ្ញើរជូនរដ្ឋបាលព្រៃឈើសាមី អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកកិច្ចអន្តរាគមន៍របស់ពួកគេ ក្នុងករណីមានបទល្មើស (ការកាប់ឈើខុសច្បាប់ និងការរុករានដីព្រៃ) ដែលកើតឡើងក្នុងដែនសហគមន៍ ។

បើទោះបីជាមានការចូលរួមពង្រឹងការអនុវត្តច្បាប់យ៉ាងសកម្មពីសមាជិកសហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើមូលដ្ឋានក៏ដោយ ក៏មានបញ្ហាមួយចំនួននៅមិនទាន់ដោះស្រាយបានទាំងស្រុងនៅឡើយ រួមមានការរុករានដីក្នុងព្រៃសហគមន៍ ពីសំណាក់អ្នកខាងក្រៅ ដែលពេលខ្លះសូម្បីតែរដ្ឋបាលព្រៃឈើមូលដ្ឋាន និង

អាជ្ញាធរដែនដី ក៏ពិបាកក្នុងការប្រឈមមុខដោះស្រាយ ។ ក្នុងករណីភាគច្រើន សមាជិកសហគមន៍នៅមិនទាន់មានសមត្ថភាព ក្នុងការសរសេរពាក្យបណ្តឹងដើម្បីបញ្ជូនទៅតុលាការនៅឡើយ ។ បន្ថែមពីលើនេះទៀតសមាជិកសហគមន៍ព្រៃឈើពុំមាន លទ្ធភាពផ្នែកហិរញ្ញវត្ថុគាំទ្រដល់ដំណើរការរៀបចំពាក្យបណ្តឹងទៅតុលាការ ហើយពួកគេក៏ពុំមានសិទ្ធនៅក្នុង ដំណើរការនីតិវិធីទៅកាន់តុលាការដោយខ្លួនឯងឡើយ [១]។ ដូច្នេះហើយសហគមន៍គ្រាន់តែអាចរាយការណ៍អំពី ករណីបទល្មើសទៅកាន់រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ គេគួតែពង្រឹងសមត្ថភាពរបស់សមាជិកសហគមន៍ព្រៃឈើ តាមរយៈការកសាងសមត្ថភាព ដើម្បីជម្រុញឲ្យពួកគេមានសមត្ថភាពរៀបចំដំណើរនីតិវិធីបទល្មើស បញ្ជូនទៅតុលាការដោយខ្លួនឯងចំណែកឯស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានវិញ គ្រាន់តែជាអ្នកផ្តល់ការសម្របសម្រួលវិញក្នុងករណីដែលចំបាច់ ។

## *ការអនុវត្ត លក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ*

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មិនត្រឹមតែចូលរួមនៅក្នុងការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ តែប៉ុណ្ណោះទេ តែពួកគេក៏បានផ្សព្វផ្សាយលទ្ធផលនេះទៅកាន់សមាជិកសហគមន៍ព្រៃឈើ និងចូលរួមអនុវត្តប្រកបដោយតម្លាភាពផងដែរ ដោយមានការគាំទ្រពីរដ្ឋបាលព្រៃឈើ និងអង្គការមិនមែនរដ្ឋាភិបាលដៃគូ ។ ការសិក្សានេះ បានរកឃើញថា សមាជិកសហគមន៍ព្រៃឈើបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលក្ខន្តិកៈសហគមន៍ព្រៃឈើ ប៉ុន្តែចំពោះអ្នកខាងក្រៅដែលមិនមែនជាសមាជិកសហគមន៍ព្រៃឈើវិញមិនបានគោរពលក្ខន្តិកៈសហគមន៍ព្រៃឈើឲ្យបានពេញលេញឡើយ ។ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក៏បានអនុវត្តបទបញ្ជាផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពតាមរយៈ កិច្ចប្រជុំជាមួយរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដៃគូ ។

បើទោះបីជារដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន បានគាំទ្រយ៉ាងខ្លាំងទៅដល់ការអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើក៏ដោយ ក៏នៅមានភាពយឺតយ៉ាវមួយចំនួនក្នុងការជួយអន្តរាគមន៍ លើការដោះស្រាយបញ្ហានានាដែលកើតមានក្នុងសហគមន៍ ហើយបញ្ហាខ្លះទៀតនៅតែមិនទាន់បានដោះស្រាយរួចរាល់នៅឡើយ ដូចជាការកាប់ឈើខុស ច្បាប់ក្នុងដែនព្រៃសហគមន៍ ទំនាស់ក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លីជាដើម ។ អនុក្រឹត្យស្តីពីការគ្រប់គ្រង សហគមន៍ព្រៃឈើ (ខែធ្នូ ឆ្នាំ ២០០៣) បានចែងពីតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រង និងសមាជិក សហគមន៍ព្រៃឈើ ថាពួកគេគ្រាន់តែអាចរាយការណ៍ និងផ្តល់ព័ត៌មានជាបន្ទាន់នូវបទល្មើសព្រៃឈើ ក្នុងតំបន់ព្រៃសហគមន៍ដល់មន្ត្រីរដ្ឋបាលព្រៃឈើដែលនៅជិតបំផុត ។ ពួកគេមិនត្រូវបានអនុញ្ញាត្តិឲ្យធ្វើសេចក្តីសម្រេចចិត្តណាមួយឡើយ ។ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជា គួរតែពិនិត្យមើលឡើងវិញនូវមាត្រាទី ២១ ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើនៅក្នុងអនុក្រឹត្យនេះដើម្បីឲ្យសហគមន៍មានសិទ្ធិអំណាចនៅក្នុងការចាត់ចែងបញ្ហានៅក្នុងដែនព្រៃសហគមន៍របស់ខ្លួន ។

---

[១] *មានករណីរដោយឡែកមួយនៃការសិក្សានេះ ក្នុងសហគមន៍ព្រៃឈើទ័ពមាន ក្នុងខេត្តកំពង់ស្ពឺ ដែលរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអាជ្ញាធរដែនដីបានផ្ទេរឲ្យសហគមន៍នូវទំនួលខុសត្រូវក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការដោយខ្លួនឯង។ ក៏ប៉ុន្តែករណីរនេះ គឺហួសពីសមត្ថភាពរបស់សហគមន៍។*

### ៥.១.៣. ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ

សហគមន៍ព្រៃឈើទាំងអស់ដែលត្រូវបានជ្រើសរើសយកមកសិក្សា មិនទាន់មានលទ្ធភាពផ្ដល់ផល-អនុផល ព្រៃឈើគ្រប់គ្រាន់សម្រាប់ធ្វើជំនួញនៅឡើយ ។ ផល-អនុផលព្រៃឈើដែលបានប្រមូលពីក្នុងដែនព្រៃសហគមន៍ បានសម្រាប់តែប្រើប្រាស់ជាលក្ខណៈគ្រួសារ និងអាចលក់ដូរតិចតួចដូចជា កូនឈើបង្គោល របង វល្លិ៍ ផ្លែឈើហូបផ្លែ ថ្នាំបុរាណ ផ្សិត និងឃ្មុំ ។ គេឃើញមានផែនការជំនួញ ផែនការតណាទានសហគមន៍ព្រៃឈើ និងផែនការប្រមូលផល-អនុផលព្រៃឈើ បានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ តែធនធានព្រៃក្នុងសហគមន៍ព្រៃឈើភាគច្រើនជាប្រភេទព្រៃរេចរឹល ដូច្នេះហើយផែនការជំនួញត្រូវបានរៀបចំឡើងបែបជាផែនការវិនិយោគស្ដារ ធនធានព្រៃឡើងវិញ និងអាចប្រមូលផលឈើជាលក្ខណៈពាណិជ្ជកម្មបានក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំខាងមុខ ។

សហគមន៍ព្រៃឈើ នៅក្នុងខេត្តកំពង់ស្ពឺ ដែលគាំទ្រដោយគម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (SFM) ក្រោមជំនួយហិរញ្ញវត្ថុពី UNDP/GEF បានរៀបចំផែនការជំនួញរបស់ខ្លួន ដាច់ដោយឡែកពីផែនការគ្រប់ គ្រងព្រៃសហគមន៍ ដោយផ្ដោតសំខាន់ទៅលើក្រុមជំនួញសហគមន៍ខ្នាតតូច ដែលមានសមាជិកចាប់ពី ៣ ទៅ ៧ គ្រួសារ ។ សមាជិកជំនួញសហគមន៍ព្រៃឈើបានប្រមូលអនុផលព្រៃឈើលក់ដូរដើម្បីបង្កើនចំណូលក្នុងគ្រួសារតែពួកគេមិនទាន់មានលទ្ធភាពច្រើនក្នុងការបរិចាកថវិកាគាំទ្រដល់សហគមន៍បានទាំងស្រុងនៅឡើយទេ ។ សហគមន៍ព្រៃឈើចំនួន ០៤ ក្នុងខេត្តកំពង់ស្ពឺ កំពុងអនុវត្តប្រមូលឫស្សីក្នុងសហគមន៍ធ្វើជំនួញ ដោយក្រុមសហគ្រាសឫស្សី បានប្រមូលទិញពីសមាជិកសហគមន៍ និងលក់បន្តរ ទៅឈ្មួញក្នុងស្រុក ដោយមានការសម្របសម្រួលគាំទ្រពីផ្នែករដ្ឋបាលព្រៃឈើបសេដ្ឋ តែទោះជាយ៉ាងនេះក្ដី ក៏ការគាំទ្រផ្លូវច្បាប់សំរាប់ដឹកជញ្ជូនផលឫស្សីចេញពីសហគមន៍ព្រៃឈើ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ និងជួយគាំទ្របន្ថែមទៀតពីរដ្ឋបាលព្រៃឈើ ។

## ៥.២. តួនាទីអាជ្ញាធរមូលដ្ឋាន

### ៥.២.១. អភិបាលកិច្ច

អាជ្ញាធរមូលដ្ឋានរួមមាន មេភូមិ ក្រុមប្រឹក្សាឃុំ និងអភិបាលខេត្ត គ្រប់លំដាប់ថ្នាក់បានចូលរួមយ៉ាងសកម្មគាំទ្រវាល់ដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ អភិបាលខេត្ត បានចូលរួមក្នុងដំណើរការអនុម័តឲ្យបង្កើតសហគមន៍ព្រៃឈើ និងគាំទ្រឲ្យមានការបង្កើតបណ្ដាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត ។ មេឃុំបានអនុម័តនូវរាល់ឯកសារពាក់ព័ន្ធនានារួមមានដីការ (សេចក្ដីសម្រេចដែលចេញដោយក្រុមប្រឹក្សាឃុំ និងមេឃុំ) ទទួលស្គាល់ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ក្រុមអជ្ញាធរក៏បានចូលរួម និងតាមដានលើដំណើរការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ និងបញ្ចូលផែនការគ្រប់គ្រងព្រៃសហគមន៍ ទៅក្នុងផែនការ និងកម្មវិធីវិនិយោគឃុំ ។ មេភូមិបានគាំទ្រ និងចូលរួមគ្រប់សកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើ ដូចជាចូលរួមប្រជុំប្រចាំខែជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងត្រួតពិនិត្យទៅលើដំណើការចាយវាយថវិការបស់សហគមន៍ ។

តាមរយៈកិច្ចសម្ភាស និងសង្កេតផ្ទាល់គេឃើញថា សមាជិកសហគមន៍ព្រៃឈើ បានចូលរួមយ៉ាងសកម្ម អនុវត្តសកម្មភាពនានា នៅពេលដែលមានគម្រោងជួយគាំទ្រដល់សហគមន៍ ហើយការចូលរួមហាក់ដូចជាមានការថយចុះ នៅពេលគម្រោងបានបញ្ចប់ ។ កិច្ចប្រជុំរវាងក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើធ្វើឡើងមិនទៀតទាត់ នៅពេលដែលគម្រោងបានបញ្ចប់ ។ នេះបញ្ជាក់ឲ្យឃើញថា ការបញ្ជ្រាបការអភិវឌ្ឍសហគមន៍ព្រៃឈើ ទៅក្នុងការរៀបចំផែនការវិនិយោគឃុំ មិនទាន់បានស៊ីជម្រៅនៅឡើយ បើទោះបីជាក្រុមប្រឹក្សាឃុំ ខិតខំប្រឹងប្រែងជាមួយការងារគ្រប់គ្រងសហគមន៍ព្រៃឈើក៏ដោយ ។

### ៥.២.២. ការពង្រឹងការអនុវត្តច្បាប់

អាជ្ញាធរមូលដ្ឋានបានចូលរួមយ៉ាងសកម្មក្នុងដំណើរការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ ២០០២) អនុក្រឹត្យ (លេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០០៣) ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាស (លេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០៦) ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ព្រមទាំងចូលរួមរៀបចំ និងអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ ចូលរួមល្បាត និងប្រជុំដោះស្រាយបទល្មើសព្រៃឈើ ។ លើសពីនេះទៀត អាជ្ញាធរមូលដ្ឋាន បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយដោះស្រាយបញ្ហានានាដែលកើតមានឡើងក្នុងសហគមន៍រួមមាន៖

- ការកាប់ឈើខុសច្បាប់ក្នុងដែនព្រៃសហគមន៍
- ការរុករានដីព្រៃ
- ដីជាន់គ្នា រវាងដីព្រៃសហគមន៍ និងដីក្រុមហ៊ុនឯកជន
- ការបែងចែកផលប្រយោជន៍ក្នុងសហគមន៍

អាជ្ញាធរដែនដី ជាពិសេសក្រុមប្រឹក្សាឃុំ បានសហការជាមួយរដ្ឋបាលព្រៃឈើដើម្បីជួយដោះស្រាយទំនាស់ដីជាពិសេសតាមរយៈការសម្របសម្រួលរវាងភាគីទំនាស់ ។ ឧទាហរណ៍ជាក់ស្តែងមួយនៅក្នុងការសិក្សានេះ ទាក់ទងទៅនឹងទំនាស់នៅក្នុងសហគមន៍ព្រៃឈើអូរសោមនៅក្នុងខេត្តកំពង់ធំ ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចអានម៉ាឌីគ្រុប ដែលត្រូវបានដោះស្រាយរួចរាល់ ដោយភាគីទាំងសង្ខាងបានទទួលស្គាល់ព្រំប្រទល់សហគមន៍ព្រៃឈើនៅ ក្នុងឆ្នាំ ២០០៩ ។

យោងតាមមាត្រាទី ៤៧ និងមាត្រាទី ៥៤ នៃច្បាប់ស្តីពីព្រៃឈើ បានកំណត់តួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ មិនអនុញ្ញាតិឲ្យធ្វើសេចក្តីសម្រេចចិត្តពាក់ពន្ធ័ការងារព្រៃឈើ ដែលនេះជាឧបសគ្គមួយធ្វើឲ្យក្រុមប្រឹក្សាឃុំមានភាពស្ទាក់ស្ទើរចូលរួមក្នុងដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែពិនិត្យមើលមាត្រាទាំងពីរ នេះឡើងវិញ ដើម្បីឲ្យផ្តល់សិទ្ធពេញលេញទៅក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើ ។

### ៥.២.៣ ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ

ភាគច្រើននៃសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ទើបតែត្រូវបានបង្កើតឡើងក្នុងរយៈខ្លី ហើយព្រៃឈើភាគច្រើនជាប្រភេទព្រៃរេចរឹល[២] ។ សហគមន៍ភាគច្រើនមិនទាន់បានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍

---

[២] *ជាឧទាហរណ៍ សហគមន៍ព្រៃឈើចំនួន ២០ ក្នុងចំណោមសហគមន៍ព្រៃឈើ ២៥ កន្លែងដែលត្រូវបានជ្រើសរើស ក្នុងការសិក្សានេះ ជាប្រភេទព្រៃរេចរឹល។*



របស់ខ្លួនរួចរាល់ទាំងស្រុងនៅឡើយដែលនេះជាបញ្ហារារាំងដល់ការប្រមូលផលឈើ ។ សហគមន៍ព្រៃឈើភាគច្រើនមានអនុផលព្រៃឈើតិចតួចតែប៉ុណ្ណោះ ដែលមានសក្តានុពលអាចប្រមូលផលបាន ។ អនុផលព្រៃឈើដែលប្រមូលបានទាំងនោះត្រូវបានយកមកប្រើប្រាស់ជា លក្ខណៈគ្រួសារ និងលក់ដូរតិចតួចនៅលើទីផ្សារ ។ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់តែងតែសម្របសម្រួល ជាមួយរដ្ឋបាលព្រៃឈើគាំទ្រដល់ការដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារ និងគាំទ្រការផ្សព្វផ្សាយបច្ចេកទេស ប្រមូលអនុផលព្រៃឈើ ។

គម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (SFM) ដែលអនុវត្តនៅក្នុងខេត្តកំពង់ស្ពឺបានគាំទ្រដល់ ការរៀបចំផែនការជំនួញ ហើយក្រុមប្រឹក្សាឃុំ បានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការនេះ ព្រមទាំង បានអនុម័តលើសំណើសុំបង្កើតក្រុមជំនួញ ផែនការជំនួញ លក្ខន្តិកៈសម្រាប់ផែនការជំនួញ និងយន្តការបែងចែកផលប្រយោជន៍ ។ ក្រុមប្រឹក្សាឃុំ ក៏បានខិតខំប្រឹងប្រែងក្នុងការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ និងវិស័យឯកជននានា តាមរយៈការពិចារណាទៅលើលទ្ធភាពក្នុងការដាក់បញ្ចូលផែនការជំនួញសហគមន៍ព្រៃឈើ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍឃុំ និងផែនការវិនិយោគឃុំ ។

## ៥.៣. តួនាទីរបស់រដ្ឋបាលព្រៃឈើ

### ៥.៣.១. អភិបាលកិច្ច

រដ្ឋបាលព្រៃឈើបានចូលរួមយ៉ាងសកម្ម លើការសម្របសម្រួល និងគាំទ្រដល់ដំណើរការនិយ័តកម្មសហគមន៍ព្រៃឈើ និងការរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ រដ្ឋបាលព្រៃឈើក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ជំហ៊ាននិងនិតិវិធីក្នុងបង្កើតសហគមន៍ព្រៃឈើ ការកំណត់ព្រំប្រទល់ព្រៃសហគមន៍ បច្ចេកទេសរុក្ខវប្បកម្ម នីតិវិធីដោះស្រាយទំនាស់ ការរៀបចំ



គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ការធ្វើសារពើភ័ណ្ឌព្រៃឈើ និងការគ្រប់គ្រងស្ថាប័នជាដើម ។ រដ្ឋបាលព្រៃឈើ បានសម្របសម្រួល ក្នុងការប្រមូលស្នាមមេដៃពីសមាជិកសហគមន៍ព្រៃឈើដើម្បីគាំទ្រការបង្កើតសហគមន៍ព្រៃឈើ និងសម្របសម្រួលបញ្ជូនពាក្យស្នើសុំបង្កើតសហគមន៍ព្រៃឈើទៅកាន់ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីស្នើសុំប្រកាសទទួលស្គាល់តំបន់សក្ដានុពលសហគមន៍ព្រៃឈើ ។ រដ្ឋបាលព្រៃឈើ ក៏បានតាមដាន និងចូលរួមគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ និងការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ រដ្ឋបាលព្រៃឈើគឺជាស្ថាប័នជំនាញដែលមានអាណត្តិក្នុងការផ្ដល់សេវាកម្ម និងជំនួយផ្នែកច្បាប់ទៅដល់សមាជិក សហគមន៍ព្រៃឈើក្នុងការដោះស្រាយទំនាស់ដែលកើនមានក្នុងដែនសហគមន៍ព្រៃឈើ ។

ការសិក្សានេះបានរកឃើញបញ្ហាមួយចំនួនរួមមាន៖

- ដំណើរនៃការស្នើសុំការពិនិត្យ និងទទួលស្គាល់តំបន់សក្ដានុពលព្រៃសហគមន៍ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលក្ខណៈស្មុគស្មាញ និងចំណាយពេលវេលាយូរ ។ ដូច្នេះហើយ គួរតែពិនិត្យឡើងវិញ និងធ្វើការកែសម្រួល នូវគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ដើម្បីឲ្យដំណើរការនេះកាន់តែប្រសើរឡើង ។
- ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ មានលក្ខណៈបច្ចេកទេសហួសពីសមត្ថភាពរបស់សហគមន៍និងដំណើរការនៃការរៀបចំចំណាយពេលវេលាយូរ ។ បើទោះបីជាសមាជិកសហគមន៍ព្រៃឈើ ទទួលបានការបណ្ដុះបណ្ដាលពីរដ្ឋបាលព្រៃឈើ ស្ដីពីការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ក៏ដោយក៏ពួកគេនៅតែមិនមានសមត្ថភាពអាចរៀបចំផែនការនេះឲ្យមានប្រសិទ្ធភាពដោយខ្លួនឯង

បានឡើយ ។ ដូច្នេះហើយរដ្ឋបាលព្រៃឈើ ចាំបាច់ត្រូវរិះរកវិធីសាស្ត្រ ក្នុងការសម្រួលដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍នេះ ឲ្យមានលក្ខណៈសាមញ្ញ ងាយស្រួល និងចំណាយពេលតិចជាមុន ។

### ៥.៣.២. ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

រដ្ឋបាលព្រៃឈើបានចូលរួមផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងព្រៃឈើ រួមមាន អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ (២០០៣) និងគោលការណ៍ណែនាំស្តីពីសហគមន៍ព្រៃឈើ (២០០៦) ដល់សមាជិកសហគមន៍ព្រៃឈើ និងអ្នកពាក់ព័ន្ធ ។ រដ្ឋបាលព្រៃឈើ ក៏បានសម្របសម្រួល និងគាំទ្រក្នុងការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ ដែលជាមូលដ្ឋានច្បាប់ឲ្យសមាជិកសហគមន៍ព្រៃឈើយល់ដឹងកាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់ខ្លួន និងការចូលរួមក្នុងការអភិវឌ្ឍសហគមន៍ ។ រដ្ឋបាលព្រៃឈើបានសម្របសម្រួលយ៉ាងសកម្មនៅក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការទប់ស្កាត់បទល្មើសឈើខុសច្បាប់ ការបរបាញ់សត្វព្រៃ ការរានដីក្នុងព្រៃសហគមន៍ ព្រមទាំងប្រមូលព័ត៌មាន និងវត្ថុតាងបទល្មើស និងដោះស្រាយទំនាស់ដីធ្លីជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ។ លើសពីនេះទៀត រដ្ឋបាលព្រៃឈើ នៅខេត្តកំពង់ធំ និងខេត្តក្រចេះ បានគាំទ្រការបង្កើតបណ្តាញសហគមន៍ព្រៃឈើចាប់ពី ថ្នាក់ឃុំ រហូតដល់ថ្នាក់ខេត្ត ក្នុងគោលដៅផ្តល់ឱកាសសម្រាប់តំណាងសហគមន៍ព្រៃឈើ ដើម្បីលើកឡើងពីបញ្ហាពាក់ព័ន្ធនានាដែលកើតមាននៅក្នុងសហគមន៍ព្រៃឈើរបស់ពួកគេ ទៅកាន់អ្នកពាក់ព័ន្ធចូលរួមដោះស្រាយ ។ ទោះបីជាយ៉ាងនេះក្តី ក៏ការអនុវត្តតួនាទីរបស់រដ្ឋបាលព្រៃឈើ នៅមានការខ្វះចន្លោះមួយចំនួនផងដែរ ។ រដ្ឋបាលព្រៃឈើ ពុំបានតាមដានដិតដល់ទៅលើ កំណត់ហេតុអង្គប្រជុំ កំណត់ហេតុបទល្មើស កំណត់ហេតុល្បាតព្រៃ និងរបាយការណ៍បទល្មើសព្រៃឈើជាក់ស្តែង ។ បច្ចុប្បន្ន សហគមន៍មិនមានសមត្ថភាពរៀបចំដំណើរការនីតិវិធីដាក់ពាក្យបណ្តឹងទៅតុលាការឡើយ ហើយស្ថាប័នជំនាញជាអ្នកដើរតួក្នុងការរៀបចំដំណើរការនេះ ។

### ៥.៣.៣. ពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ

រដ្ឋបាលព្រៃឈើមូលដ្ឋាន បានសហការគ្នាយ៉ាងជិតស្និទ្ធ ជាមួយដៃគូរអភិវឌ្ឍ ក្នុងការរៀបចំផែនការជំនួញ និងក្រុមជំនួញអនុផលព្រៃឈើខ្នាតតូច (ក្រុមជំនួញផ្សិត ក្រុមជំនួញជំឡុង ក្រុមជំនួញបន្លែ ក្រុមជំនួញអង្រ្កង និងក្រុមឥណទានសហគមន៍ព្រៃឈើ) ។ ខណ្ឌរដ្ឋបាលព្រៃឈើបរសេដ្ឋ ក្នុងខេត្តកំពង់ស្ពឺ បានគាំទ្រសហគមន៍ព្រៃឈើចំនួន ៤ ក្នុងការអនុវត្តផែនការជំនួញ ដែលកំពុងដំណើរប្រមូលផលឬស្សីក្នុងលក្ខណៈជំនួញ ។ មកដល់ពេលនេះ ជំនួញឬស្សីបានប្រព្រឹត្តទៅដោយរលូន ប៉ុន្តែបច្ចុប្បន្ននេះ នៅមិនទាន់មានការគាំទ្រផ្លូវច្បាប់ នៅឡើយចំពោះការដឹកជញ្ជូនផលឬស្សី ទៅលក់ឲ្យឈ្មួញកណ្តាលក្នុងស្រុក ដែលនេះទាមទារឲ្យមាន ការគាំទ្របន្ថែមទៀត ។



# ៦. ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៦.១. ការសន្និដ្ឋាន

របាយការណ៍នេះបានឆ្លុះបញ្ចាំងឲ្យឃើញថា តួនាទីរបស់អ្នកពាក់ព័ន្ធនានាពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើ ក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ សមាជិកសហគមន៍ព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីរដ្ឋបាលព្រៃឈើបានចូលរួម និងគាំទ្រពេញលេញ ក្នុងដំណើរការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើរួមមាន ការសម្របសម្រួល ដើម្បីឲ្យសហគមន៍មានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើស្របតាមក្របខណ្ឌគតិយុត្តិ ។ ចំពោះសហគមន៍ព្រៃឈើដែលទទួលបានកិច្ចព្រមព្រៀង បានទាក់ទាញឲ្យមានការចូលរួមបន្ថែមទៀត ពីសំណាក់សមាជិកសហគមន៍ និងកាន់តែមាន ទំនួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រង និងការពារព្រៃឈើ ព្រមទាំងមានកិច្ចសហការល្អ ជាពិសេសជាមួយមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ។ លើសពីនេះទៀត អាជ្ញាធរមូលដ្ឋាន តែងតែជួយអន្តរាគមន៍ នៅពេលមានបទល្មើសកើតឡើងក្នុងដែនសហគមន៍ ។ ក្រោយពីបានចុះកិច្ចព្រមព្រៀង រួចមកសហគមន៍ព្រៃឈើភាគច្រើនបានទទួលការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាលដៃគូ និងពីជំនាញរដ្ឋបាលព្រៃឈើ ក្នុងការបណ្តុះបណ្តាលសមាជិកសហគមន៍ព្រៃឈើ ស្តីពីការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងផែនការជំនួញដែលនេះនឹងធ្វើឲ្យគណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ មានសមត្ថភាពសមស្របក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើរបស់ពួគេឲ្យមាននិរន្តរភាព ។ ការបង្កើតយន្តការតាមដានសកម្មភាពនានា តាមរយៈបណ្តាញសហគមន៍ព្រៃឈើ (ពីថ្នាក់ឃុំ រហូតដល់ថ្នាក់ខេត្ត) បានបង្ហាញឲ្យឃើញនូវប្រសិទ្ធភាព នៃការចែករំលែកបទពិសោធន៍ និងជាយន្តការមួយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការជួយដោះស្រាយទំនាស់ ។

មកដល់ពេលនេះ សហគមន៍មានលទ្ធភាពប្រមូលអនុផលព្រៃឈើសម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងលក់ដូរបន្តិចបន្តួចតែប៉ុណ្ណោះ ។ ផែនការជំនួញមួយចំនួនត្រូវបានរៀបចំឡើងនិងកំពុងអនុវត្តនៅក្នុងព្រៃសហគមន៍ ដែលជាប្រភេទព្រៃរេចរឹល ដោយផ្តោតជាសំខាន់ក្នុងការប្រមូលអនុផលព្រៃឈើសម្រាប់ការប្រើប្រាស់ជា លក្ខណៈគ្រួសារតែប៉ុណ្ណោះ ។ សហគមន៍ព្រៃឈើមួយចំនួនមានសក្តានុពលចំពោះការប្រមូលផលឈើ ប៉ុន្តែសមាជិកសហគមន៍មិនទាន់មានសមត្ថភាពក្នុងការប្រមូលផលឈើទាំងនោះសម្រាប់លក្ខណៈពាណិជ្ជកម្មនៅឡើយ បើទោះបីជាមានផែនការប្រមូលផល ដែលត្រូវបានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ ។ ការផ្តល់លទ្ធភាពឲ្យសហគមន៍ក្នុងការប្រមូលផលឈើជាលក្ខណៈជំនួញតាមរយៈសហគមន៍ព្រៃឈើ នៅមានឧបសគ្គនៅឡើយ ។ សហគមន៍ព្រៃឈើត្រូវបានលើកទឹកចិត្តក្នុងការប្រមូលផលឈើលក្ខណៈជំនួញ ដែលនេះ ជាប្រភពនៃការទ្រទ្រង់ជីវភាពរស់នៅក៏ដោយ ក៏សហគមន៍បានជួបប្រទះនូវឧបសគ្គមួយចំនួនរួមមាន៖

- ការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ និងដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំណាយពេលវេលាយូរ និងធ្វើឲ្យសហគមន៍មានការនឿយណាយ ។ (សូមមើលកថាខណ្ឌខាងលើ)
- ពុំទាន់មានគោលការណ៍ណែនាំបច្ចេកទេសស្តីពីការប្រមូលផលឈើនៅក្នុងសហគមន៍ព្រៃឈើច្បាស់លាស់ដើម្បីឲ្យរដ្ឋបាលព្រៃឈើ ធ្វើការណែនាំទៅដល់អ្នកអនុវត្តផ្ទាល់នៅមូលដ្ឋាន ក៏ដូច

ជាសហគមន៍ព្រៃឈើ ។ ដោយសារពុំទាន់មានគោលការណ៍ណែនាំនេះហើយ ទើបក្រុមបច្ចេកទេសសម្រាប់ការប្រមូលផលឈើ របស់ក្រុមហ៊ុនព្រៃសម្បទានត្រូវបានលើកទឹកចិត្តឲ្យយកប្រើប្រាស់ក្នុងសហគមន៍ ។ ក៏ប៉ុន្តែដោយសារតែនីតិវិធីនេះដែលត្រូវបានគេរៀបចំឡើងសម្រាប់អាជីវកម្មធំៗ មានលក្ខណៈ បច្ចេកទេស និងស្មុគស្មាញខ្លាំង មិនសមស្របទៅនឹងសហគមន៍ ដូច្នេះហើយវាមិនបានទាក់ទាញ ចំណាប់អារម្មណ៍របស់សហគមន៍ឲ្យចូលរួមឡើយ ។ បន្ថែមពីលើភាពស្មុគស្មាញផ្នែកបច្ចេកទេសការ ប្រមូលផលឈើលក្ខណៈពាណិជ្ជកម្មនេះ ទាមទារការប្រើប្រាស់ទុនច្រើន ផងដែរនិងម្យ៉ាងវិញទៀត សហគមន៍យល់ថាពួកគេជាធម្មតាមិនអាចប្រកួតប្រជែងផ្នែកពាណិជ្ជកម្មជាមួយឈើដែល បានមកពីប្រភពខុសច្បាប់នោះឡើយ ។

ការចូលរួមរបស់អ្នកពាក់ព័ន្ធមានភាពប្រសើរគួរឲ្យកត់សម្គាល់ តែការចូលរួមនេះភាគច្រើនមាននៅតែក្នុងដំណាក់កាលគ្រប់គ្រង និងការពារព្រៃឈើតែប៉ុណ្ណោះ ។ សហគមន៍ព្រៃឈើនៅតែពឹងផ្អែកលើការគាំទ្រពីប្រភពខាងក្រៅទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍន៍ ដោយសារតែសមាជិកសមាគមន៍ព្រៃឈើមិនទាន់មានសមត្ថភាពក្នុងការទាញយកផលប្រយោជន៍ពីសហគមន៍ព្រៃឈើសម្រាប់ការទ្រទ្រង់សហគមន៍ដោយខ្លួនឯងបាន ។ ចំណេះដឹងនិងសមត្ថភាពរបស់គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើនៅមានកម្រិតនៅឡើយទាក់ទងទៅនឹងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ដែលនេះទាមទារឲ្យមានការគាំទ្រ ផ្នែកបច្ចេកទេសពីរដ្ឋបាលព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ។ យោងតាមលទ្ធផលវិភាគទៅលើលិខិតបទដ្ឋានដែលមានស្រាប់ តួនាទីរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាននៅមានកម្រិតនៅឡើយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ទៅលើការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ ស្ថាប័នជំនាញពាក់ព័ន្ធ មិនមានលទ្ធភាពផ្តល់ការគាំទ្រពេញលេញចំពោះករណីមួយចំនួន ហើយពេលខ្លះទៀត ការអន្តរាគមន៍របស់ស្ថាប័នទាំងនេះមានភាពយឺតយ៉ាវ និងមានប្រសិទ្ធភាពតិចតួចនៅក្នុងការដោះស្រាយទំនាស់ដែលកើតឡើងពីការប្រើប្រាស់ដីជាន់គ្នា ។

## ៦.២. ការផ្តល់អនុសាសន៍

អ្នកពាក់ព័ន្ធនានា បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគាំទ្រការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃដល់សហគមន៍មូលដ្ឋាន ។ ដូច្នេះដើម្បីធានាបានថាការចូលរួមចំណែករបស់ពួកគេមានប្រសិទ្ធភាព និងដើម្បីឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញតាមរយៈការសិក្សានេះ ក្រុមការងារដែលបានចុះសិក្សាបានលើកឡើងនូវ អនុសាសន៍មួយចំនួនដូចខាងក្រោម៖

### ៦.២.១. អភិបាលកិច្ច

១. ផ្តល់ការបណ្តុះបណ្តាលស្តីពី ការសរសេររបាយការណ៍ ការសរសេរកំណត់ហេតុ ការគ្រប់គ្រងថវិកាទៅដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ គឺជាអាទិភាពដើម្បីអោយពួកគាត់មានសមត្ថភាពអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើឲ្យបានពេញលេញ ។

២. គួរតែពិនិត្យមើលឡើងវិញនូវបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីរិះរកយុទ្ធសាស្ត្រក្នុងការបង្កើនចំនួន ចូលរួមរបស់ស្ត្រីក្នុងជួរសមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ការកសាងសមត្ថភាពគឺជាការចាំបាច់សម្រាប់ស្ថាប័នជំនាញពាក់ព័ន្ធ និងអង្គការមិន

មែនរដ្ឋាភិបាលដៃគូដើម្បីពង្រឹងការអនុវត្ត នៅក្នុងការគាំទ្រសកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើ ដោយផ្ដោត ទៅលើការវាយតម្លៃពីតម្រូវការរបស់ស្ត្រី ក្នុងបរិបទអភិវឌ្ឍសហគមន៍ព្រៃឈើ ការវាយតម្លៃពីតម្រូវការរបស់ ស្ត្រីដែលផ្ដល់ឲ្យស្ត្រីនូវតួនាទី និងភារកិច្ចនៅក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការកំណត់យុទ្ធសាស្ត្រដើម្បីពង្រឹងសមត្ថភាពរបស់ស្ត្រី តាមរយៈការបណ្ដុះបណ្ដាល ព្រមទាំងតួនាទីរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងព្រៃឈើក្នុងបរិបទបណ្ដាញសហគមន៍ព្រៃឈើ ។

៣. គួរពិចារណាទៅលើគំរូអនុវត្តដ៏សមស្របសម្រាប់ការប្រើប្រាស់ក្នុងសហគមន៍ព្រៃឈើ និងគាំទ្រ ដើម្បីជម្រុញឲ្យប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ស្របច្បាប់ពីសហគមន៍ ។ ឧទាហរណ៍៖ សមាជិកសហគមន៍ព្រៃឈើបានស្នើសុំដាំប្រភេទឈើដែលឆាប់ផ្ដល់ផលដូចជា ស្វាយចន្ទី ឬ ដើមអាកាស្យាជាដើម នៅក្នុងតំបន់ស្តារព្រៃឈើឡើងវិញក្នុងព្រៃសហគមន៍ ដើម្បីបង្កើនប្រភពចំណូល និងវិនិយោគនៅក្នុងការគ្រប់គ្រងព្រៃឈើ ។ សហគមន៍ព្រៃឈើគួរតែទទួលបានការគាំទ្រចំពោះទំនាក់ទំនងរបស់ពួកគេជាមួយវិស័យឯកជនជាពិសេសក្នុងការធ្វើពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ។ សហគមន៍ព្រៃឈើគួរតែត្រូវបានគេពង្រីកបន្ថែមទៀត ដើម្បីធានាបាននូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច-សង្គមដែលចំបាច់ និងបង្កើតបទបញ្ញត្តិពាក់ព័ន្ធនានាដែលធានាបានថា ផលប្រយោជន៍ទាំងនេះបានទៅដល់សហគមន៍ជាអតិបរិមា និងលឿនជាងមុន ។

៤. ក្រុមប្រឹក្សាឃុំមានភាពសកម្មភាពក្នុងការគាំទ្រការអភិវឌ្ឍសហគមន៍ព្រៃឈើនៅ ពេលដែលពួកគេមានតួនាទីនៅក្នុងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ពួកគាត់មានសមត្ថភាពសម្របសម្រួលជាមួយ ខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងអាចដោះស្រាយបញ្ហាមានប្រសិទ្ធិភាព ។ ដូច្នេះគួរពិចារណាតួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ដើម្បីឲ្យពួកគាត់មានលទ្ធភាពប្រសើរជាងមុន ក្នុងការប្រើប្រាស់តួនាទីបានពេញលេញចូលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ ។

## ៦.២.២ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

៥. ដូចដែលបានកត់សម្គាល់ពីខាងលើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ (ឆ្នាំ ២០០៣) ដែលអនុញ្ញាត្តិឲ្យគណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ មានសិទ្ធិគ្រាន់តែអាចរាយការណ៍និងផ្ដល់ព័ត៌មានជាបន្ទាន់នូវបទល្មើសព្រៃឈើក្នុងតំបន់ព្រៃសហគមន៍ដល់មន្ត្រីរដ្ឋបាលព្រៃឈើដែលនៅជិតបំផុត ។ ពួកគេមិនបានអនុញ្ញាត្តិឲ្យធ្វើសេចក្ដីសម្រេចចិត្តណាមួយឡើយ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណា និងពិនិត្យឡើងវិញលើមាត្រាទី ២១ ស្តីពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ ដើម្បីឲ្យពួកគេមានសិទ្ធបន្ថែមទៀតក្នុងការចាត់ចែងដោះស្រាយបញ្ហានៅក្នុងដែនព្រៃសហគមន៍ ។

៦. សមត្ថភាពរបស់សមាជិកសហគមន៍ព្រៃឈើ គួរតែត្រូវបានពង្រឹង តាមរយៈការកសាងសមត្ថភាព និងជម្រុញឲ្យពួកគេអាចរៀបចំដំណើរការនីតិវិធីបទល្មើសបញ្ជូនទៅតុលាការដោយខ្លួនឯង ចំណែកឯស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានវិញគ្រាន់តែជាអ្នកផ្ដល់ការសម្របសម្រួល ក្នុងករណីចំបាច់។

៧. ការល្បាតត្រូវបានគេមើលឃើញថា គឺជាយន្តការដ៏មានប្រសិទ្ធិភាព ក្នុងការទប់ស្កាត់សកម្មភាពល្មើសនានានៅក្នុងព្រៃសហគមន៍ ។ សកម្មភាពល្បាតគឺជាភារកិច្ចរបស់សមាជិកសហគមន៍ព្រៃឈើ ដូចដែលបានចែងនៅក្នុងបទលក្ខន្តិកៈសហគមន៍ព្រៃឈើ ។ បន្ថែមពីលើនេះទៀតសមាជិកសហគមន៍ព្រៃឈើបាន បង្ហាញឲ្យឃើញនូវឆន្ទៈ ក្នុងចូលរួមក្នុងក្រុមល្បាត ។ តែទោះជាយ៉ាងនេះក្តីក៏សកម្មភាពចុះល្បាតកន្លង មកបានប្រើប្រាស់ថវិកា ដែលជាវិភាគទានរបស់សមាជិកសហគមន៍ព្រៃឈើតាមការស្ម័គ្រចិត្ត និងមិនធានានិរន្តរភាពឡើយ ។ បច្ចុប្បន្ននេះការអនុវត្តសកម្មភាពក្នុងសហគមន៍ព្រៃឈើភាគច្រើន រួមទាំងការចុះល្បាតផងនោះ គឺពឹងផ្អែកស្ទើទាំងស្រុងលើគម្រោងគាំទ្ររបស់ដៃគូអភិវឌ្ឍ ។ ដូច្នេះហើយដើម្បីធានានិរន្តរភាពរយៈពេលវែង រាជរដ្ឋាភិបាលគួរតែពិចារណាទៅ លើការវិភាជន៍ថវិកាជាតិចូលទៅក្នុងផែនការវិនិយោគឃុំ ជាពិសេសសម្រាប់ការអភិវឌ្ឍសហគមន៍ព្រៃឈើ ។

## ៦.២.៣ ពាណិជ្ជកម្មសហគមន៍ព្រៃឈើ

៨. ដូចដែលបានកត់សម្គាល់ពីខាងលើ ដោយសារពុំទាន់មានគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការប្រមូលផលឈើត្រឹមត្រូវ (ក្នុងបរិបទសហគមន៍ព្រៃឈើ) សម្រាប់ត្រួសត្រាយផ្លូវដល់រដ្ឋបាលព្រៃឈើ នៅកម្រិតថ្នាក់ជាតិ និងខណ្ឌរដ្ឋបាលព្រៃឈើ ដូចនេះហើយវានៅតែជាឧបសគ្គក្នុងការជម្រុញផលឈើសម្រាប់ជំនួញនៅក្នុងសហគមន៍ព្រៃឈើ ។ មានការណែនាំ លើកទឹកចិត្តពីរដ្ឋបាលព្រៃឈើឲ្យប្រើ ប្រាស់ក្រុមបច្ចេកទេសសម្រាប់ប្រមូលផលឈើ របស់ក្រុមហ៊ុនព្រៃសម្បទានមកប្រើក្នុងព្រៃសហគមន៍។ តែដោយសាតែនីតិវិធីនវ មានលក្ខណៈបច្ចេកទេសស្មុគស្មាញ និងមិនសមស្របទៅនឹងបរិបទសហគមន៍ ដូច្នេះមិនបានទាក់ទាញចំណាប់អារម្មណ៍របស់សហគមន៍ឲ្យចូលរួមឡើយ ។ បន្ថែមពីលើភាពស្មុគស្មាញផ្នែកបច្ចេកទេស ការប្រមូលផលឈើលក្ខណៈពាណិជ្ជកម្មនេះទាមទារការប្រើប្រាស់ទុនច្រើន និងម្យ៉ាងទៀត សហគមន៍យល់ថាពួកគេជាធម្មតាមិនអាចប្រកួតប្រជែងជាមួយឈើដែលបានមកពីប្រភពខុសច្បាប់នោះឡើយ ។ ម្យ៉ាងទៀតសំរាប់សហគមន៍ព្រៃឈើដែលមានសក្តានុពលផ្តល់ផលឈើពាណិជ្ជកម្ម មិនគួរកំណត់ពេលរងចាំក្រោយរយៈពេល ៥ ឆ្នាំឡើយប្រសិនបើសហគមន៍មានធនធានសមស្របអាចប្រមូលបាន ។

៩. ផែនការគ្រប់គ្រងព្រៃសហគមន៍ និងផែនការជំនួញដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដែលកន្លងមកតែងតែពឹងផ្អែកការគាំទ្រហិរញ្ញវត្ថុពីគម្រោងដៃគូអភិវឌ្ឍទាំងស្រុង។ ខណ្ឌរដ្ឋបាលព្រៃឈើ ដែលជាអ្នកទទួលខុសត្រូវសំខាន់ក្នុងការផ្តល់ការណែនាំបច្ចេកទេសគាំទ្រដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្នុងការអនុវត្តផែនការទាំងនេះ នឹងប្រឈមបញ្ហាថវិកាគាំទ្រ ។ ដូចនេះដើម្បីធានានិរន្តរភាពក្នុងការគ្រប់គ្រង រាជរដ្ឋាភិបាលគួរពិចារណាវិភាជន៍កញ្ចប់ថវិកាជាតិសម្រាប់ខណ្ឌរដ្ឋបាលព្រៃឈើ ក្នុងការគាំទ្រអនុវត្តផែនការគ្រប់គ្រងនិងផែនការជំនួញសហគមន៍ព្រៃឈើ ។

# ឯកសារយោង

រដ្ឋបាលព្រៃឈើ ឆ្នាំ ២០១៥ ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា ឆ្នាំ ២០១៥

រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០៦ គោលការណ៍ណែនាំពីអំពីសហគមន៍ព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០០៦ ប្រកាស្តីពីគោលការណ៍ណែនាំស្តីពីសហគមន៍ព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០២ ច្បាប់ស្តីពីព្រៃឈើ (២០០២a) ថ្ងៃទី ៣១ ខែសីហា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៣ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ថ្ងៃទី ២០ ខែធ្នូ ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១០ កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩ ខែធ្នូ ឆ្នាំ ២០១០ ភ្នំពេញ កម្ពុជា

ផែនការគ្រប់គ្រងព្រៃសហគមន៍របស់សហគមន៍ព្រៃឈើគោលដៅ

ផែនការជំនួញរបស់សហគមន៍ព្រៃឈើគោលដៅ



# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១. តារាងពេលវេលានៃការវាយតម្លៃ

ផែនការចុះវាយតម្លៃពីវាយតម្លៃអំពីស្ថានភាពជាក់ស្តែង និងភាពប្រឈមនានាចំពោះសហគមន៍ព្រៃឈើក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើព្រៃឈើ នៅក្នុងប្រទេសកម្ពុជានៅខេត្តក្រចេះ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ។

| ល.រ | កាលបរិច្ឆេទ | សហគមន៍/ស្ថាប័ន | ឃុំ | ស្រុក | ខេត្ត | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| 1 | 08/11/2015 | សហគមន៍ព្រៃឈើ ស្រែរនាម | ឃ្សឹម | ស្នួល | ក្រចេះ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 2 | 09/11/2015 | សហគមន៍ព្រៃឈើ អន្លង់វៀន | កន្ទួត | ចិត្របុរី | ក្រចេះ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា |
| 3 | 09/11/2015 | សហគមន៍ព្រៃឈើ កន្ទួត | កន្ទួត | ចិត្របុរី | ក្រចេះ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 4 | 10/11/2015 | សហគមន៍ព្រៃឈើ ប៉ាក្លែរ | រលួសមានជ័យ | សំបូរ | ក្រចេះ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 5 | 11/11/2015 | សហគមន៍ព្រៃឈើ រលួស | រលួសមានជ័យ | សំបូរ | ក្រចេះ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 6 | 14/11/2015 | សហគមន៍ព្រៃឈើ តាំងបំពង់ | តាសាល | ឱរ៉ាល់ | កំពង់ស្ពឺ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 7 | 15/11/2015 | សហគមន៍ព្រៃឈើ ទំពមាន | ទព័មាន | ថ្ពង | កំពង់ស្ពឺ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 8 | 16/11/2015 | សហគមន៍ព្រៃឈើ ជ្រោះដំបង | ជាំសង្កែ | ភ្នំស្រួច | កំពង់ស្ពឺ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធាវ៉ា |
| 9 | 16/11/2015 | សហគមន៍ព្រៃឈើ ជ្រោះស្វាយ | អូរ | ភ្នំស្រួច | កំពង់ស្ពឺ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆរី<br>កញ្ញា នន ណារីន |
| 10 | 17/11/2015 | សហគមព្រៃឈើ ជ្រោះពង្រ | អូរ | ភ្នំស្រួច | កំពង់ស្ពឺ | លោក អេង ប៉ូឡូ |
| 11 | 17/11/2015 | សហគមន៍ព្រៃឈើ ចង្អោរតូច | ស្រង់ | គងពិសី | កំពង់ស្ពឺ | កញ្ញា ស៊ុយ សុធាវ៉ា<br>លោក សេម រីដា |

| ល.រ | កាលបរិច្ឆេទ | សហគមន៍/ស្ថាប័ន | ឃុំ | ស្រុក | ខេត្ត | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| 12 | 17/11/2015 | សហគមន៍ព្រៃឈើ ភ្នំស្រង់ | ស្រង់ | គងពិសី | កំពង់ស្ពឺ | អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 13 | 18/11/2015 | សហគមន៍ព្រៃឈើ ស្វាយរំពារ | ស្វាយរំពារ | បសេដ្ឋ | កំពង់ស្ពឺ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 14 | 18/11/2015 | ប្រជុំជាមួយមន្ត្រីរដ្ឋបាលព្រៃឈើនៅផ្នែករដ្ឋបាលព្រៃឈើបសេដ្ឋ | | | កំពង់ស្ពឺ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 15 | 23/11/2015 | សហគមន៍ព្រៃឈើ ក្បាលអូរក្រញាក | មានរិទ្ធិ | សណ្ដាន់ | កពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 16 | 24/11/2015 | សហគមន៍ព្រៃឈើ អូរក្រញ៉ូង | មានរិទ្ធិ | សណ្ដាន់ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 17 | 24/11/2015 | សហគមន៍ព្រៃឈើ ឃុំសុចិត្រ | សុចិត្រ | សណ្ដាន់ | កំពង់ធំ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 18 | 25/11/2015 | សហគមន៍ព្រៃឈើ ព្រៃហុំ | ដំរីស្លាប់ | កំពង់ស្វាយ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 19 | 25/11/2015 | សហគមព្រៃឈើ ត្រពាំងរូង | ជ័យ | កំពង់ស្វាយ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 20 | 25/11/2015 | សហគមន៍ព្រៃឈើ អូរសោម | សាលាវិស័យ | ប្រាសាទបល្ល័ង្គ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 21 | 25/112015 | សហគមព្រៃឈើ កន្សែងវាល | សាលាវិស័យ | ប្រាសាទបល្ល័ង្គ | កំពង់ធំ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 22 | 26/11/2015 | សហគមន៍ព្រៃឈើ សាលាឆ្កោ | សាលាវិស័យ | ប្រាសាទបល្ល័ង្គ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 23 | 26/11/2015 | សហគមព្រៃឈើ អូរចាំស្រីត្រដក់ពង | ស្រើង | ប្រាសាទសំបូរ | កំពង់ធំ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 24 | 27/11/2015 | សហគមន៍ព្រៃឈើ អូរកំបុត | គោល | ប្រាសាទសំបូរ | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា<br>លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |
| 25 | 28/11/2015 | សហគមន៍ព្រៃឈើ ព្រៃក្បាលបី | ទីពោធិ៍ | សន្ទុក | កំពង់ធំ | លោក អេង ប៉ូឡូ<br>កញ្ញា ស៊ុយ សុធារ៉ា |
| 26 | 28/11/2015 | សហគមន៍ព្រៃឈើ ត្រពាំងសណ្ដាន់ | ទីពោធិ៍ | សន្ទុក | កំពង់ធំ | លោក សេម រីដា<br>អ្នកស្រី ស៊ឹម ឆវី<br>កញ្ញា នន ណាវីន |

## ឧបសម្ព័ន្ធទី ២. តារាងលទ្ធផលនៃការវាយតម្លៃនៅខេត្តក្រចេះ

ខេត្តក្រចេះមានសហគមន៍ព្រៃឈើសរុបចំនួន ៩៦ កន្លែង និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន ២៧ សហគមន៍ព្រៃឈើ ក្នុងនោះមានសហគមន៍ព្រៃឈើចំនួន ០៦ បានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងបានទទួលឯកភាពជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ។ តាមផែនការដែលបានគ្រោងទុកក្រុមការងារវាយតម្លៃបានជ្រើសរើសសហគមន៍ព្រៃឈើចំនួន ១០ មកធ្វើការសិក្សា ប៉ុន្តែតាមស្ថានភាពជាក់ស្តែងដោយសារតែផ្លូវមានការលំបាកក្នុងការធ្វើដំណើរ ហើយសហគមន៍ព្រៃឈើ ខ្លះត្រូវឆ្លងទន្លេ ដែរត្រូវចំណាយពេលវេលាយូរក្រុមការងារបានសម្រេចធ្វើការជ្រើសរើសសហគមន៍ព្រៃឈើចំនួន ០៥ មកធ្វើការសិក្សា រួមមាន៖ ១. សហគមន៍ព្រៃឈើស្រែរនាម ២. សហគមន៍ព្រៃឈើអន្ទង់វៀន ៣. សហគមន៍ព្រៃឈើកន្ទួត ៤. សហគមន៍ព្រៃឈើប៉ាក្លែ និង ៥. សហគមន៍ព្រៃឈើរលួស។ ទន្ទឹមនឹងគ្នានោះដែរក្រុមការងារបានជួបពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានដូចជា មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត។

រូបទី ៤. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ



## តារាងទី ២. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដី

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| អភិបាលកិច្ច | ការចូលរួម | • មានការចូលរួម និងគាំទ្រពីសមាជិកភាគច្រើន (៦៥%) ក្នុងដំណើការបង្កើត<br>• សមាជិកសហគមន៍ព្រៃឈើបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលគាំទ្រ ដំណើការបង្កើតសហគមន៍ព្រៃឈើ<br>• សមាជិកសហគមន៍បានចូលរួមបង្កើត និងអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុង<br>• សមាជិកសហគមន៍ព្រៃឈើបានចូលរួមក្នុងការងារយាមល្បាតព្រៃដោយមានការចែកជាក្រុម និងវេនច្បាស់លាស់<br>• សមាជិកសហគមន៍ព្រៃឈើចូលរួមប្រជុំរៀបចំបង្កើតសហគមន៍ព្រៃឈើស្របតាមកម្មវិធីព្រៃឈើជាតិ<br>• កិច្ចប្រជុំរៀបចំផ្សព្វផ្សាយ | • បទល្មើស មានចំនួនច្រើនក្នុងតំបន់ និងក្រៅសហគមន៍ធ្វើអោយការចូលរួមធ្លាក់ចុះដោយសារតែការទប់ស្កាត់ ឬបង្ក្រាបទទួលបានលទ្ធផលតិចតួច<br>• ការទទួលខុសត្រូវ (គ្រាន់តែមកចូលរួម) មានកំរិតទាប ដោយគិតថាព្រៃរបស់គណកម្មការសហគមន៍ព្រៃឈើ ពុំទាន់ឃើញ ផលប្រយោជន៍ដោយផ្ទាល់<br>• អ្នកខាងក្រៅ (ចំណាកស្រុក) |
| | តួនាទីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | • បានអនុវត្តតាមលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ | • សមាជិកភាគច្រើនចូលរួមតាមៗគ្នា ភាគច្រើនមិនទាន់យល់ពីការទទួលខុសត្រូវរបស់ខ្លួន<br>• សមាជិកសហគមន៍ខ្លះគិតថាព្រៃសហគមន៍ជាការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ |
| | តម្លាភាព | • រាល់ការសម្រេចចិត្តលើការអភិវឌ្ឍក្នុងសហគមន៍ផ្អែកលើមតិសមាជិកភាគច្រើន<br>• ការបែងចែកផលប្រយោជន៍ដោយសមធម៌<br>• មានការតាមដាន និងត្រួតពិនិត្យនូវចំណូលចំណាយផ្សេងៗរបស់គណកម្មការគ្រប់គ្រងតាមរយៈកិច្ចប្រជុំប្រចាំខែ<br>• មានបណ្តាញសហគមន៍ព្រៃឈើពីមូលដ្ឋានដល់ថ្នាក់ជាតិដើម្បីពង្រឹង និងបង្ហាញតម្លាភាពការគ្រប់គ្រងសហគមន៍ព្រៃឈើដល់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ | • មិនទាន់មានយន្តការពិនិត្យទៅលើតម្លាភាពការធ្វើពាណិជ្ជកម្មរបស់សហគមន៍ដោយមិនមានធនធានធ្វើអាជីវកម្មច្បាស់លាស់<br>• ការប្រជុំបង្ហាញពីតលម្លាភាពរបស់សហគមន៍មិនបានទៀងទាត់ |
| | ការឆ្លើយតប | • រាយការណ៍ជូនក្រុមប្រឹក្សាឃុំដើម្បើជួយអន្តរាគមន៍ក្នុងករណីមានបទល្មើសព្រៃឈើកើតឡើង<br>• រាយការណ៍ ពីករណីបទល្មើសជាក់ស្តែងទៅសង្កាត់រដ្ឋបាលព្រៃឈើដើម្បីចងក្រងសំណុំរឿងតាមនិតិវិធីនៃច្បាប់ស្តីពីព្រៃឈើក្រុមប្រឹក្សាឃុំ | ពេលខ្លះមានការយឺតយ៉ាវដោយសារៈ<br>• ក្រុមប្រឹក្សាឃុំ ឬ រដ្ឋបាលព្រៃឈើមូលដ្ឋានជាប់រវល់<br>• បទល្មើសច្រើនមន្ត្រីជំនាញមានចំនួនតិច<br>• ការទំនាក់ទំនងមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងគណកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនៅមានកំរិត (ដំណើរការឯកសារចងក្រង) |

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| ពង្រឹងការអនុវត្តច្បាប់ | ការការពារ ទប់ស្កាត់ និងការបង្ក្រាប | • សហគមន៍បានរៀបចំក្រុមល្បាត និងបានដើរយាមល្បាត<br>• មានការចូលរួមខ្ពស់បន្ទាប់ពីមានកិច្ចព្រមព្រៀង<br>• ការងារល្បាត<br>• សមាជិកដែលចូលព្រៃសហគមន៍ដើម្បីរុករកអនុផលព្រៃឈើ ឬឃ្វាលគោក្របីរាយការណ៍ទាន់ពេលវេលា | • ប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន<br>• ថវិកាគាំទ្រមិនទៀងទាត់អាស្រ័យលើអង្គការមកជួយ<br>• ថវិកាសម្រាប់ដើរល្បាតដែលបានពីសមាជិកមានភាពអសកម្មដោយសារតែមិនមានទំនុកចិត្ត<br>• ដំណើរការល្បាតមិនបានទៀងទាត់ |
| | ការត្រួតពិនិត្យ និងរបាយការណ៍ | • ធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាឃុំជាប្រចាំពីសកម្មភាពដែលបានអនុវត្តប្រចាំខែ<br>• មានការទុកដាក់ឯកសារ | • របាយការណ៍ពុំបានទៀងទាត់ |
| ពាណិជ្ជកម្ម | ធនធានព្រៃសហគមន៍ និងទីផ្សារ | • មានកូនឈើតូចៗ និងអនុផលមួយចំនួន | • សហគមន៍ព្រៃឈើមិនទាន់បានផ្តល់ផលសម្រាប់ទ្រទ្រង់ជីវភាពបាននៅឡើយ |
| | ការគាំទ្រផ្លូវច្បាប់ | • ច្បាប់ស្តីពីព្រៃឈើនៃមាត្រា២៤, ២៦, ៤០, ៤១, ៤២, ៤៣, ៤៤, ៥៣, និងមាត្រា ៥៨(៣១/សីហា/២០០២)<br>• អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ (លេខ៧៩អនក្រ.បកចុះ០២/ធ្នូ/២០០៣)<br>• ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២១/កក្កដា/២០០៦) | • មិនទាន់យល់ច្បាស់ពីនិតិវិធី<br>• ចំណេះដឹងមានកំរិតទាប |

# ឧបសម្ព័ន្ធទី ៣ តារាងលទ្ធផលនៃវាយតម្លៃនៅខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺមានសហគមន៍ព្រៃឈើចំនួន ២៥ កន្លែង បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន ១៧ សហគមន៍ និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយមានការឯកភាពជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ បានចំនួន ៨ សហគមន៍។ ដើម្បីធ្វើការប្រមូលពត៌មានពីការអនុវត្តជាក់ស្តែងនៃការអនុវត្តតួនាទីរបស់សមាជិកសហគមន៍ព្រៃឈើ ក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ក្រុមការងារវាយតម្លៃ បានជ្រើសរើសសហគមន៍ព្រៃឈើចំនួន ០៨ មកធ្វើការសិក្សារួមមាន៖ ១. សហគមន៍ព្រៃឈើតាំងបំពង់ ២. សហគមន៍ព្រៃឈើទ័ពមាន ៣. សហគមន៍ព្រៃឈើជ្រោះដំបង ៤. សហគមន៍ព្រៃឈើជ្រោះស្វាយ ៥. សហគមន៍ព្រៃឈើជ្រោះពង្រ ៦. សហគមន៍ព្រៃឈើចង្អោតូ ៧. សហគមន៍ព្រៃឈើភ្នំស្រង់ និង ៨. សហគមន៍ព្រៃឈើស្វាយរំពារ។ ទន្ទឹមនឹងគ្នានោះដែរក្រុមការងារបានជួបពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានដូចជា មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអាជ្ញធរឃុំ ។

រូបទី ៥. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ស្ពឺ



តារាងទី ៣. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដី

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| អភិបាលកិច្ច | ការចូលរួម | • មានការចូលរួម និងគាំទ្រពីសមាជិកភាគច្រើន<br>• មានអង្គការជួយគាំទ្រថវិកា<br>• ការងារល្បាត<br>• កិច្ចប្រជុំរៀបចំបង្កើតសហគមន៍ព្រៃឈើ<br>• កិច្ចប្រជុំរៀបចំផ្សព្វផ្សាយ<br>• ដោះស្រាយបញ្ហាកាប់រានដីព្រៃ | • បញ្ហារាំងស្ទួតប៉ះពាល់ដល់កង្វល់ជីវភាព<br>• សមាជិកសហគមន៍មានការយល់ដឹងនៅមានកំរិតទាប<br>• ភាគច្រើនមានតែគណកម្មការសហគមន៍ព្រៃឈើចូលរួមប្រជុំខណៈមិនមានថវិកាលើកទិកចិត្ត<br>• មិនទាន់ទទួលបានផលប្រយោជន៍ដោយផ្ទាល់ក្រៅពីអនុផលព្រៃឈើ<br>• ពេលផ្លាស់មន្ត្រីថ្មីរបស់រដ្ឋបាលព្រៃឈើមូលដ្ឋានមិនមានឯកសារតម្កល់ទុក |
| | តួនាទី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | • បានអនុវត្តតាមលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ<br>• រាល់ការអនុវត្តសកម្មភាពក្នុងសហគមន៍គឺយកលក្ខន្តិកៈសហគមន៍ជាគោល | • សមាជិកសហគមន៍ខ្លះគិតថាព្រៃសហគមន៍ជាការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ព្រោះមិនទាន់យល់ច្បាស់ពីតួនាទីរបស់ខ្លួន |
| | តម្លាភាព | • រាល់ការសម្រេចចិត្តលើការអភិវឌ្ឍន៍ក្នុងសហគមន៍ផ្អែកលើមតិសមាជិកភាគច្រើន<br>• ការបែងចែកផលប្រយោជន៍ដោយសមធម៌<br>• តាមដាន និងត្រួតពិនិត្យនូវចំណូលចំណាយផ្សេងៗ<br>• មានបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត និងមូលដ្ឋានដើម្បីពង្រឹងការគ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុដោយខ្លួនឯង | • ការបញ្ចេញយោបល់មានកំរិតទាប (ចំណេះដឹងមានកំរិត) |
| | ការឆ្លើយតប | • ពេលមានបទល្មើសកើតឡើងសហគមន៍តែងតែស្វែងរកអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ និង រដ្ឋបាលព្រៃឈើមូលដ្ឋាន | ពេលខ្លះមានការយឺតយ៉ាវដោយសារៈ<br>• ក្រុមប្រឹក្សាឃុំ ឬរដ្ឋបាលព្រៃឈើមូលដ្ឋានជាប់រវល់<br>• បទល្មើសច្រើន មន្ត្រីជំនាញមានចំនួនតិច<br>• ការទំនាក់ទំនងរវាងមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងគណកម្មការសហគមន៍នៅមានកំរិត (មិនមានថវិកាគាំទ្រ) |
| ពង្រឹងការអនុវត្តច្បាប់ | ការការពារ ទប់ស្កាត់ និងការបង្ក្រាប | • មានការចូលរួមខ្ពស់បន្ទាប់ពីមានកិច្ចព្រមព្រៀង<br>• មានផែនការគ្រប់គ្រង<br>• ការងារល្បាត<br>• សមាជិកដែលចូលព្រៃសហគមន៍ដើម្បីរករកអនុផលព្រៃឈើ ឬឃ្វាលគោក្របីរាយការណ៍ទាន់ពេលវេលា<br>• រាយការណ៍ជូនក្រុមប្រឹក្សាឃុំជូនអន្តរាគមន៍ក្នុងការធ្វើកិច្ចសន្យា | • ថវិកាគាំទ្រមិនទៀងទាត់អាស្រ័យលើថវិកាគាំទ្រពីអង្គការ<br>• ការយល់ដឹងពីតួនាទី និងសិទ្ធិអំណាចមានកំរិត (គណកម្មការ និងសមាជិកសហគមន៍) |
| | ការត្រួតពិនិត្យ និងរបាយការណ៍ | • ធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាឃុំជាប្រចាំពីសកម្មភាពដែលបានអនុវត្តប្រចាំខែ<br>• រាយការណ៍ ពីករណីបទល្មើសជាក់ស្តែងទៅសង្កាត់រដ្ឋបាលព្រៃឈើដើម្បីចងក្រងសំណុំរឿងតាមនិតិវិធីនៃច្បាប់ស្តីពីព្រៃឈើ<br>• មានប្រពន្ធ័ទុកដាក់ឯកសារ | • ការរៀបចំរបាយការណ៍មិនទៀងទាត់<br>• ឯកសារពុំបានទុកនៅមួយកន្លែង |

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| ពាណិជ្ជកម្ម | ធនធានព្រៃ សហគមន៍ និងទីផ្សារ | • មានកូនឈើតូចៗ និងអនុផលមួយចំនួន<br>• មានក្រុមដកហូតដើមឬស្សី<br>• ទំនាក់ទំនងទីផ្សារដើមឬស្សី<br>• ពេលដកហូតជូនដំណឹងទៅរដ្ឋបាលព្រៃឈើមូលដ្ឋាន | • បច្ចេកទេសដកហូត<br>• ការកត់ត្រាទិន្នន័យដកហូត<br>• កិច្ចសន្យាលក់ដូរដើមឬស្សី<br>• មិនទាន់យល់ច្បាស់ពីបទដ្ឋានផ្លូវច្បាប់ (ប្រមូល និងដឹកជញ្ជូន) |
| | ការគាំទ្រផ្លូវច្បាប់ | • ច្បាប់ស្តីពីព្រៃឈើនៃមាត្រា២៤, ២៦, ៤០, ៤១, ៤២, ៤៣, ៤៤, ៥៣, និងមាត្រា ៥៨(៣១/សីហា/២០០២)<br>• អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ(លេខ៧៩អនក្រ.បកចុះ០២/ធ្នូ/២០០៣)<br>• ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២១/កក្កដា/២០០៦) | • មិនទាន់យល់ច្បាស់ពីនិតិវិធី<br>• ចំណេះដឹងមានកំរិតទាប |

## ឧបសម្ព័ន្ធទី ៤.  តារាងលទ្ធផលនៃការវាយតម្លៃនៅខេត្តកំពង់ធំ

ខេត្តកំពង់ធំមានសហគមន៍ព្រៃឈើចំនួន ៨២ កន្លែង និងបានចុះកិច្ចព្រមព្រៀងបានចំនួន ៦៦ សហគមន៍ព្រៃឈើ ។  មានសហគមន៍ព្រៃឈើចំនួន ១២ បានរៀបចំផែនការគ្រប់គ្រង និងមានការឯកភាពជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ ។ ដើម្បីស្វែងយល់ពីការអនុវត្តជាក់ស្តែង នៃការអនុវត្តតួនាទីសហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើ ក្រុមការងារបានជ្រើសរើសសហគមន៍ព្រៃឈើចំនួន១២ សហគមន៍មកធ្វើការសិក្សារួមមាន៖ ១. សហគមន៍ព្រៃឈើព្រៃក្បាលអូរក្រញ៉ាក ២. សហគមន៍ព្រៃឈើអូរក្រញូង ៣. សហគមន៍ព្រៃឈើឃុំសុចិត្រ ៤. សហគមន៍ព្រៃឈើព្រៃហ៊ុំ  ៥. សហគមន៍ព្រៃឈើត្រពាំងរូង ៦. សហគមន៍ព្រៃឈើអូរសោម ៧. សហគមន៍ព្រៃឈើកន្សែងវាល ៨. សហគមន៍ព្រៃឈើសាលាឆ្កោ ៩. សហគមន៍ព្រៃឈើអូរចាំស្រីត្រដក់ពង ១០. សហគមន៍ព្រៃឈើអូរកំបុត ១១. សហគមន៍ព្រៃឈើព្រៃក្បាលបី និង ១២. សហគមន៍ព្រៃឈើត្រពាំងសណ្តាន់ ។  ទន្ទឹមនឹងគ្នានោះដែរក្រុមការងារបានជួបពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានដូចជា  មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន អង្គការម្លប់បៃតង អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD) និងបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត។

រូបទី ៦. ផែនទីសហគមន៍ព្រៃឈើដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ធំ



### តារាងទី ៤. លទ្ធផលសង្ខេបនៃកិច្ចប្រជុំជាមួយគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដី

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| អភិបាលកិច្ច | ការចូលរួម | • មានការចូលរួម និងគាំទ្រពីសមាជិកភាគច្រើន<br>• មានអង្គការជួយគាំទ្រថវិកា<br>• ការងារល្បាត<br>• កិច្ចប្រជុំរៀបចំបង្កើតសហគមន៍ព្រៃឈើ<br>• កិច្ចប្រជុំរៀបចំផ្សព្វផ្សាយ<br>• យល់ឃើញពីផលប្រយោជន៍ព្រៃសហគមន៍ដោយសារមានក្រុមហ៊ុននៅក្បែរ<br>• គណកម្មការគ្រប់គ្រងមានភាពច្បាស់លាស់ និងសាមគ្គីគ្នាល្អគិតពិផលប្រយោជន៍រួម<br>• បង្ហាញលទ្ធផលបង្ក្រាប និងប្រាក់ផាកពិន័យជាសាធារណៈ | • ការទទួលខុសត្រូវ (គ្រាន់តែមកចូលរួម) នៅមានកំរិត ដូចជាគិតថាព្រៃរបស់គណកម្មការសហគមន៍ព្រៃឈើ<br>• បញ្ហាកាប់រានដីព្រៃ (សាលាឆ្កោ) មិនអាចគ្រប់គ្រងបាន<br>• មានការចូលរួមច្រើនតែការបញ្ចេញយោបល់មានកំរិតទាបពុំទាន់ឃើញផលប្រយោជន៍ដោយផ្ទាល់ |
| | តួនាទី លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | • បានអនុវត្តតាមលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ<br>• រាល់ការអនុវត្តសកម្មភាពក្នុងសហគមន៍គឺយកលក្ខន្តិកៈសហគមន៍ជាគោល | • សមាជិកសហគមន៍ខ្លះគិតថាព្រៃសហគមន៍ជាការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសហគមន៏ព្រៃឈើ ព្រោះមិនទាន់យល់ច្បាស់ពីតួនាទីរបស់ខ្លួន |
| | តម្លាភាព | • រាល់ការសម្រេចចិត្តលើការអភិវឌ្ឍន៍ក្នុងសហគមន៍ផ្អែកលើមតិសមាជិកភាគច្រើន<br>• ការបែងចែកផលប្រ យោជន៍ដោយសមធម៌<br>• តាមដាន និងត្រួតពិនិត្យនូវចំណូលចំណាយផ្សេងៗ<br>• មានបណ្តាញសហគមន៍ព្រៃឈើថ្នាក់ជាតិ និងមូលដ្ឋានដើម្បីពង្រឹងការគ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុដោយខ្លួនឯង។ | |
| | ការឆ្លើយតប | មានការឆ្លើយតបទាន់ពេលវេលាពី៖<br>• ក្រុមប្រឹក្សាឃុំក្នុងករណីមានបទល្មើសព្រៃឈើកើតឡើង<br>• រដ្ឋបាលព្រៃឈើមូលដ្ឋានអន្តរាគមន៍ទាន់ពេល<br>• ទំនាក់ទំនងល្អជាមួយអង្គការពាក់ព័ន្ធ | • ពេលខ្លះមានការយឺតយ៉ាវដោយសារ៖<br>• ក្រុមប្រឹក្សាឃុំ ឬរដ្ឋបាលព្រៃឈើមូលដ្ឋានជាប់រវល់<br>• បទល្មើសច្រើន មន្រ្តីជំនាញមានចំនួនកំណត់<br>• លទ្ធផលនៃការចងក្រងសំណុំរឿងមិនត្រូវបានឆ្លើយតបជាហេតុធ្វើអោយមានការយល់ផ្សេងៗគ្នា ឬបាត់បង់ជំនឿលើមន្រ្តីជំនាញ<br>• បញ្ហាឯកសារពេលមានការផ្លាស់ប្តូរមន្រ្តីរដ្ឋបាលព្រៃឈើមូលដ្ឋាន |

| សមាសភាគ | សកម្មភាព | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|---|
| ពង្រឹងការអនុវត្តច្បាប់ | ការការពារទប់ស្កាត់បង្ក្រាប | • បានរៀបចំក្រុមល្បាតការងារល្បាត និងមានផែនការល្បាត<br>• ប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ<br>• សមាជិកដែលចូលព្រៃសហគមន៍ដើម្បីរុករកអនុផលព្រៃឈើ ឬឃ្វាលគោក្របីរាយការណ៍ទាន់ពេលវេលា<br>• មានព្រំប្រទល់ជាប់ជាមួយក្រុមហ៊ុន<br>• ធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាឃុំជាប្រចាំពីសកម្មភាពដែលបានអនុវត្តប្រចាំខែ<br>• រាយការណ៍ជូនក្រុមប្រឹក្សាឃុំជូនអន្តរាគមន៍ក្នុងការធ្វើកិច្ចសន្យា និងពិន័យចំពោះសមាជិកប្រព្រឹត្តល្មើស<br>• រាយការណ៍ ពីករណីបទល្មើសជាក់ស្តែងទៅសង្កាត់រដ្ឋបាលព្រៃឈើដើម្បីចងក្រងសំណុំរឿងតាមនិតិវិធីនៃច្បាប់ស្តីពីព្រៃឈើ | • មិនមានថវិកាគាំទ្រមិនទៀងទាត់អាស្រ័យលើអង្គការមកជួយ<br>• មធ្យោបាយទំនាក់ទំនង-វិទ្យុទាក់ទង<br>• ប្រជាជនដែលមិនមានព្រៃសហគមន៍<br>• កន្លែងខ្លះមានតម្រូវការខ្ពស់ |
| | ការត្រួតពិនិត្យ និងរបាយការណ៍ | • ធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាឃុំជាប្រចាំពីសកម្មភាពដែលបានអនុវត្តប្រចាំខែ<br>• រាយការណ៍ ពីករណីបទល្មើសជាក់ស្តែងទៅសង្កាត់រដ្ឋបាលព្រៃឈើដើម្បីចងក្រងសំណុំរឿងតាមនិតិវិធីនៃច្បាប់ស្តីពីព្រៃឈើ<br>• មានប្រពន្ធ័ទុកដាក់ឯកសារ | • ការរៀបចំរបាយការណ៍មិនបានទៀងទាត់<br>• ឯកសារពុំបានទុកនៅមួយកន្លែង |
| ពាណិជ្ជកម្ម | ធនធានព្រៃសហគមន៍ និងទីផ្សារ | • មានកូនឈើតូចៗ និងអនុផលមួយចំនួន<br>• ក្រុមប្រមូលទឹកឃ្មុំ<br>• ក្រុមប្រមូលផ្តៅ<br>• ក្រុមប្រមូលកូនឈើជន្លួល/បង្គោល | • ថវិកាមានចំនួនកំណត់សម្រាប់ប្រមូលទិញ<br>• ការកត់ត្រាទិន្នន័យការដកហូត<br>• កំរំពេលកម្មដកហូតមិនទាន់ច្បាស់លាស់ (មិនគិតជាភាគរយតាមតម្លៃទីផ្សារ) |
| | ការគាំទ្រផ្លូវច្បាប់ | • ច្បាប់ស្តីពីព្រៃឈើនៃមាត្រា២៤, ២៦, ៤០, ៤១, ៤២, ៤៣, ៤៤, ៥៣, និងមាត្រា ៥៨(៣១/សីហា/២០០២)<br>• អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ(លេខ៧៩អនក្រ.បកចុះ០២/ធ្នូ/២០០៣)<br>• ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (២១/កក្កដា/២០០៦) | • មិនទាន់យល់ច្បាស់ពីនិតិវិធី<br>• ចំណេះដឹងមានកំរិតទាប |

## ឧបសម្ព័ន្ធទី ៥. បញ្ជីសំណួរ

### ១. អភិបាលកិច្ចសហគមន៍ព្រៃឈើ

*ការចូលរួម*

- តើអ្នកបានចូលរួមក្នុងដំណើការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើដែរឬទេ? ជំហ៊ានទីប៉ុន្មាន ឬសកម្មភាពអ្វី?
- តើអ្នកបានចូលរួមក្នុងដំណើការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ដៃឬទេ? ជំហ៊ានទីប៉ុន្មាន ឬសកម្មភាពអ្វី?
- តើអ្នកធ្លាប់បានចូលរួមប្រជុំសហគមន៍ដែរ ឬទេ? ចំនួនប៉ុន្មានដង ?
- តើអង្គប្រជុំបានពិភាក្សាបញ្ហាអ្វីខ្លះ? តើសមាជិកអង្គប្រជុំមានឱកាសបញ្ចេញមតិ ឬលើកជាសំណូមពរអ្វីក្នុងអង្គប្រជុំដែរឬទេ?
- តើអ្នកបានចូលរួមធ្វើការសំរេចចិត្តក្នុងការងារអភិវឌ្ឍន៍សហគមន៍អ្នកដែរ ឬទេ? តើបញ្ហាអ្វីខ្លះ?
- តើធ្លាប់មានទំនាស់ក្នុងសហគមន៍ដែរឬទេ? ជាទំនាស់អ្វីខ្លះ? តើទំនាស់នោះដោះស្រាយបានដែរឬទេ? តើការដោះស្រាយនោះមានដំណើរការដូចម្តេច?
- តើអ្នកបានផ្តល់ពត៌មានដែលទាក់ទងនឹងបទល្មើសព្រៃឈើដល់អ្នកពាក់ពន្ធ័ដែរឬទេ? ផ្នែកណាខ្លះ? តើអ្នកបានផ្តល់ពត៌មាន ដោយវិធីណា? តាមរយៈនរណាខ្លះ?
- តើអ្នកបានឃើញការឆ្លើយតបបែបណាខ្លះ ចំពោះបទល្មើសទាំងនោះ ពីអ្នកពាក់ពន្ធ័ទាំងអស់ បន្ទាប់ពីបានទទួលពត៌មានពីអ្នក?
- តើអ្នកយល់ថាវិធានការណ៍ទាំងនោះសមស្របដែរឬទេ? ហេតុអ្វី?
- តើអ្នកធ្លាប់បានទទួលពត៌មានអ្វីខ្លះពាក់ព័ន្ធនឹងព្រៃឈើពីអ្នកពាក់ពន្ធ័?

*តួនាទី លក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ*

- តើសហគមន៍ព្រៃឈើរបស់អ្នកមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែរឬទេ?
- តើអ្នកបានចូលរួមក្នុងការរៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ព្រៃឈើដែរឬទេ?
- តើសមាជិកសហគមន៍ព្រៃឈើ បានគោរពតាមបទបញ្ជារដែរ ឬទេ?
- តើមានការអនុវត្តពិន័យដែរឬទេ ក្នុងករណីមិនគោរពតាមបទបញ្ជាផ្ទៃក្នុង?
- តើរដ្ឋបាលព្រៃឈើបានចូលរួមអ្វីខ្លះក្នុងការអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហមន៍ព្រៃឈើ?
- តើអាជ្ញាធរដែនដី និងអ្នកពាក់ពន្ធ័ផ្សេងទៀត បានចូលរួមចំណែកអ្វីខ្លះក្នុងអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហមន៍ព្រៃឈើ?

*តម្លាភាព*

- តើគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើបានរៀបចំប្រជុំទៀងទាត់ដែរ ឬទេ?
- តើញ្ហាអ្វីខ្លះដែលបានលើកមកពិភាក្សា និងសំរេចក្នុងអង្គប្រជុំ?
- តើលទ្ធផល ឬការសំរេចរបស់អង្គប្រជុំបានផ្សព្វផ្សាយដល់សមាជិកសហគមន៍ ឬស្ថាប័នពាក់ពន្ធ័ដែរ ឬទេ?

- តើសហគមន៍ព្រៃឈើមានរបាយការណ៍អ្វីខ្លះ?
- តើរបាយការណ៍ទាំងនោះផ្ញើជូនស្ថាប័នណាខ្លះ?
- តើឯកសាររបស់សហគមន៍ព្រៃឈើ រក្សាទុកនៅកន្លែងណា? នរណាជាអ្នកទទួលខុសត្រូវ?
- តើឯកសាររបស់សហគមន៍ព្រៃឈើមានអ្វីខ្លះ?
- តើអ្នកណាខ្លះ មានសិទ្ធិក្នុងការមើលឯកសារឬព័ត៌មានទាំងនោះ?
- តើឯកសារ ឬព័ត៌មានទាំងនោះត្រូវបានចែករំលែកយ៉ាងដូចម្តេច ឬតាមរយៈអ្វី?

*ការឆ្លើយតប*

- តើសមាជិកសហគមន៍ត្រូវជូនដំណឹងដល់អ្នកណាខ្លះពេលជួបប្រទះនូវបទល្មើសព្រៃឈើ?
- តើការជូនដំណឹងនោះត្រូវធ្វើឡើងដូចម្តេច?
- តើគគសពមានអន្តរាគមន៍ដូចម្តេចខ្លះក្រោយពីទទួលបានព័ត៌មានបទល្មើសព្រៃឈើ?
- តើគគសពធ្វើអ្វីខ្លះក្នុងពេលទទួលបានពត៌ស្តីពីបទល្មើសព្រៃឈើពីសមាជិកសហគមន៍?
- តើអាជ្ញាធរដែនដី រដ្ឋបាលព្រៃឈើនិងអ្នកពាក់ពន្ធ័ធ្វើអន្តរាគមន៍ដូចម្តេចបន្ទាប់ពី បានទទួលពត៌មានបទល្មើសព្រៃឈើពីសហគមន៍?
- តើអ្នកគិតថាយន្តការនៃការផ្តល់ពត៌មាននេះយ៉ាងដូចម្តេចដែរ?

## ២. ពង្រឹងការអនុវត្តច្បាប់

*ការការពារ ទប់ស្កាត់ និងបង្ក្រាប*

- ដើម្បីការពារ ទប់ស្កាត់ និងបង្រ្កាបរាល់បទល្មើសដែលកើតមានឡើងក្នុងសហគមន៍ តើសហគមន៍បានរៀបចំវិធានការណ៍បែបណា?
- តើការអនុវត្តលក្ខន្តិកៈ និងបទបញ្ជារផ្ទៃក្នុងសហគមន៍មានប្រសិទ្ធិភាពដែរឬទេក្នុងការការពារ ទប់ស្កាត់ និងបង្រ្កាបរាល់បទល្មើសក្នុងសហគមន៍? ព្រោះអ្វី?
- តើភ្នាក់ងាររដ្ឋាភិបាលដែលពាក់ពន្ធ័ និងអង្គការក្រៅរដ្ឋាភិបាលគួរតែគាំទ្រអ្វីខ្លះដល់សហគមន៍ក្នុងការធ្វើផែនការ និងរៀបចំសកម្មភាពការពារ ទប់ស្កាត់ និងបង្រ្កាប បទល្មើសព្រៃឈើក្នុងសហគមន៍?
- តើសហគមន៍ និងមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន មាននិតិវិធិអ្វីខ្លះក្នុងការអនុវត្តច្បាប់ព្រៃឈើ និងលក្ខន្តិកៈសហគមន៍ព្រៃឈើ (សមាជិកសហគមន៍ និងអ្នក ក្រៅដែលមិនមែនជាសមាជិកសហគមន៍ព្រៃឈើ)?

*ការត្រួតពិនិត្យ និងរបាយការណ៍*

- តើមានកសារអ្វីខ្លះរបស់សហគមន៍ដែលបានរក្សាទុក ?
- តើសហគមន៍មានប្រពន្ធ័ត្រួតពិនិត្យសកម្មភាពការងារដូចម្តេច?
- តើមានសំណុំរឿងអ្វីខ្លះដែលបានចងក្រងទុកក្នុងសហគមន៍? ដើម្បីអ្វី?

## ៣. ឧបសគ្គ និងឱកាសសំរាប់ សមាជិកសហគមន៍ព្រៃឈើ ដើម្បីបង្កើនជីវភាពសហគមន៍មូលដ្ឋានតាមរយៈការលក់ផលព្រៃឈើ

*ធនធានសហគមន៍ព្រៃឈើ និងទីផ្សារ*

- តើនៅក្នុងព្រៃសហគមន៍មានផល និងអនុផលព្រៃឈើអ្វីខ្លះ?
- តើការប្រើប្រាស់ផល និងអនុផលព្រៃឈើមានដំណើការដូចម្តេច?
- តើធ្វើដូចម្តេចដើម្បីឲ្យការប្រើប្រាស់ផល និងអនុផលព្រៃឈើនៅក្នុងព្រៃសហគមន៍ ប្រកបដោយនិរន្តរភាព?
- ផល អនុផលព្រៃឈើអ្វីខ្លះដែលហូរចូលទីផ្សារ? តើដំណើការដូចម្តេច ?

*ការគាំទ្រពីស្ថាប័នច្បាប់*

- តើការប្រមូលផល អនុផលព្រៃឈើ មានដំណើរការដូចម្តេច?
- តើសន្និធិ និងការដឹកជញ្ជូន ផល អនុផលព្រៃឈើសហគមន៍ដែលប្រមូលបានមានដំណើការដូចម្តេច?
- តើមានចំណុចណាខ្លះនៃច្បាប់ព្រៃឈើ និងលក្ខន្តិកៈសហគមន៍ព្រៃឈើ
  បានគាំទ្រដល់ពាណិជ្ជកម្មព្រៃឈើ?

# ឧបសម្ព័ន្ធទី ៦

## *ការណែនាំសំរាប់ការវាយតម្លៃ ពីតួនាទីរបស់សហគមន៍ព្រៃឈើក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងធ្វើពាណិជ្ជកម្មផលិតផលសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា*

| គោលបំណង | សមាសភាគនៃការវាយតម្លៃ | ព័ត៌មាន | ប្រភពព័ត៌មាន | វិធីសាស្រ្តដើម្បីទទួលបានព័ត៌មាន |
|---|---|---|---|---|
| គោលបំណងជាក់លាក់ទី ១ | ១.១. អភិបាលកិច្ចសហគមន៍ព្រៃឈើ | | | |
| កំណត់ចំណុចខ្លាំង និងខ្សោយនៃអភិបាលកិច្ចសហគមន៍ព្រៃឈើ និងការអនុវត្តច្បាប់ដោយ សហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើមូលដ្ឋាន | ការចូលរួម | • និតិវិធីនិយតកម្មសហគមន៍ព្រៃឈើ និងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ។<br>• ការធ្វើសេចក្តីសំរេចចិត្តក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ<br>• ការដោះស្រាយទំនាស់<br>• ការចែករំលែកព័ត៌មានស្តីពីសហគមន៍ព្រៃឈើជាមួយអ្នកពាក់ពន្ធ័ (ការកាប់ឈើខុសច្បាប់ ការរុករានដីក្នុងសហគមន៍ព្រៃឈើ)<br>• សកម្មភាពអភិវឌ្ឍន៍សហគមន៍ព្រៃឈើ | • គណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ (គគសព) សមាជិកសហគមន៍ព្រៃឈើ<br>• ក្រុមប្រឹក្សាឃុំ<br>• ក្រុមប្រឹក្សាស្រុក<br>• រដ្ឋបាលព្រៃឈើមូលដ្ឋាន<br>• គណៈកម្មការបណ្តាញសហគមន៍ព្រៃឈើឈើមូលដ្ឋាន | • និត្យឯកសារឡើងវិញ (Desk reviews)<br>• សំភាសន៍បុគ្គល<br>• ពិភាក្សាក្រុម (FGDs)<br>• ការសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ<br>• សិក្ខាសាលា បង្ហាញលទ្ធផលនៃការប៉ាន់ប្រមាណដល់អ្នកពាក់ពន្ធ័ |
| | តួនាទី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | • ការអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងព្រៃឈើ<br>• ការស្វែងយល់លក្ខន្តិកៈសហគមន៍ព្រៃឈើ របស់គណៈកម្មាការគ្រប់គ្រង និងសមាជិកសហគមន៍ព្រៃឈើ<br>• តួនាទីភ្នាក់ងាររដ្ឋាភិបាលក្នុងការអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ និងបទបញ្ជាផ្ទៃក្នុង<br>• ទណ្ឌកម្ម និងពិន័យ | | |
| | តម្លាភាព | • កិច្ចប្រជុំទៀងទាត់របស់គគសព និងសមាជិកសហគមន៍ព្រៃឈើ<br>• កិច្ចប្រជុំប្រចាំឆ្នាំរបស់សហគមន៍ ព្រៃឈើ<br>• ប្រពន្ធ័របាយការណ៍សហគមន៍ ព្រៃឈើ<br>• ការទុកដាក់ឯកសារ និងការចែករំលែកព័ត៌មាន | | |

| គោលបំណង | សមាសភាគនៃការវាយតម្លៃ | ព័ត៌មាន | ប្រភពព័ត៌មាន | វិធីសាស្ត្រដើម្បីទទួលបានព័ត៌មាន |
|---|---|---|---|---|
| | ការឆ្លើយតប | • យន្តការសំរាប់សមាជិកសហគមន៍ព្រៃឈើដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពី ការកាប់ឈើខុសច្បាប់ក្នុងសហគមន៍ ព្រៃឈើ<br>• ឆ្លើយតបពីគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើដល់សំណើពីសមាជិកសហគមន៍ព្រៃឈើ<br>• ការអន្តរាគមន៍ និងគាំទ្រពីអាជ្ញាធរដែនដី និងរដ្ឋបាលព្រៃឈើមូលដ្ឋាន ក្នុងការឆ្លើយតបទៅសំណើពីគណៈកម្មាការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសមាជិកសហគមន៍ព្រៃឈើ | | |
| | ១.២- ពង្រឹងការអនុវត្តច្បាប់ | | | |
| | ការការពារ និងបង្ក្រាប | • អ្នកពាក់ពន្ធ័យល់ដឹងពីច្បាប់ និងលក្ខន្តិកៈសហគមន៍ព្រៃឈើ<br>• កិច្ចសហការរវាងភ្នាក់ងាររដ្ឋាភិបាលដែលពាក់ពន្ធ័ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកក្នុងការធ្វើផែនការ និងរៀបចំសកម្មភាពការពារ និងបង្ក្រាប<br>• សមត្ថភាពរបស់សហគមន៍ និងអាជ្ញាធររដ្ឋាភិបាលដែលទាក់ទងជាមួយការគ្រប់គ្រងទំនាស់<br>• អន្តរាគមន៍របស់រដ្ឋបាលព្រៃឈើ និងអ្នកពាក់ពន្ធ័ផ្សេងទៀតក្នុងការធ្វើផែនការ និងរៀបចំសកម្មភាពការពារ និងបង្ក្រាប<br>• ពង្រឹកអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងព្រៃឈើ<br>• សហគមន៍យល់ដឹងច្បាប់ព្រៃឈើ<br>• តួនាទីរបស់អ្នកពាក់ពន្ធ័ក្នុងការធ្វើផែនការ និងការរៀបចំសកម្មភាពការពារ និងបង្ក្រាប ជាពិសេស គគសពសមាជិកសហគមន៍ព្រៃឈើ និងភ្នាក់ងារជំនាញរដ្ឋាភិបាល<br>• ភាពជាម្ចាស់របស់សហគមន៍លើព្រៃឈើ<br>• អន្តរាគមន៍របស់រដ្ឋបាលព្រៃឈើ អ្នកពាក់ពន្ធ័ ផ្សេងៗនៅថ្នាក់មូលដ្ឋាន និង ភ្នាកងារជំនាញរដ្ឋាភិបាលក្នុងការគាំទ្រសហគមន៍ដើម្ប នុវត្តលក្ខន្តិកៈសហគមន៍ និងបទបញ្ជាផ្ទៃក្នុង | | |

| គោលបំណង | សមាសភាគនៃការវាយតម្លៃ | ព័ត៌មាន | ប្រភពព័ត៌មាន | វិធីសាស្ត្រដើម្បីទទួលបានព័ត៌មាន |
|---|---|---|---|---|
| | ការត្រួតពិនិត្យ និងរបាយការណ៍ | • ប្រពន្ធ័កត់ត្រា និងធ្វើរបាយការណ៍នៅថ្នាក់សហគមន៍<br>• ប្រពន្ធ័កត់ត្រានៅកំរិតរអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើមូលដ្ឋាន<br>• ប្រពន្ធ័របាយការណ៍រឿង (ករណី) ដើម្បីកត់ត្រា និងរាយការណ៍ពីស្ថានភាពថ្មីៗ នៃរឿង (ករណី) | | |
| គោលបំណងជាក់លាក់ទី 2 | | | | |
| កំណត់ឧបសគ្គ និងឱកាសសំរាប់សមាជិកសហគមន៍ព្រៃឈើ ដើម្បីបង្កើនជីវភាពសហគមន៍មូលដ្ឋានតាមរយៈការលក់ផលព្រៃឈើ | ធនធានសហគមន៍ព្រៃឈើ និងទីផ្សារ | • ផលព្រៃឈើដែលអាចរកបាន (សារពើភណ្ឌ័) រួមទាំងអនុផលព្រៃឈើ នៅក្នុងព្រៃសហគមន៍ ។<br>• កំណត់ការប្រើប្រាស់ ប្រកបដោយនិរន្តរភាព នៃផលព្រៃឈើរួមទាំងអនុផលព្រៃឈើនៅក្នុងព្រៃសហគមន៍។<br>• រចនាសម្ព័ន្ធទីផ្សារ (សង្វាក់ផលិតកម្ម) និងតម្រូវការផលព្រៃឈើ រួមទាំងអនុផលព្រៃឈើមកពីព្រៃសហគមន៍<br>• ការបង្កើនប្រាក់ចំណូលរបស់សមាជិកសហគមន៍ព្រៃឈើពីផល និង អនុផលព្រៃឈើ<br>• សិទ្ធិរបស់សមាជិកសហគមន៍ ដើម្បីប្រើប្រាស់ និងទីផ្សារផល និងអនុផលព្រៃឈើ<br>• ដំណោះស្រាយទំនាស់ទាក់ទងជាមួយការប្រើប្រាស់ធនធានព្រៃឈើ ក្នុងសហគមន៍ព្រៃឈើ | • គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ<br>• សមាជិកសហគមន៍ព្រៃឈើ<br>• ផែនកាគ្រងសហគមន៍ព្រៃឈើ<br>• ក្រុមប្រឹក្សាឃុំ<br>• ក្រុមប្រឹក្សាស្រុក<br>• រដ្ឋបាលព្រៃឈើមូលដ្ឋាន គណៈកម្មការបណ្តាញសហគមន៍ព្រៃឈើ<br>• ផ្នែកវិស័យឯកជន | • ពិនិត្យឯកសារឡើងវិញ (Desk reviews)<br>• សំភាសន៍បុគ្គល<br>• ពិភាក្សាក្រុម (FGDs)<br>• ការសំភាសន៍ជាមួយអ្នកផ្តល់ពត៌ មានសំខាន់ៗ (KII)<br>• សិក្ខាសាលា បង្ហាញលទ្ធផលនៃការប៉ាន់ប្រមាណដល់អ្នកពាក់ពន្ធ័ |
| | ការគាំទ្រពីស្ថាប័នច្បាប់ | • យន្តការចុះបញ្ជីពាណិជ្ជកម្ម ផ្លូវការនិងមិនផ្លូវការសំរាប់ផល និងអនុផល ព្រៃឈើ<br>• ការបង់ពន្ធផល និងអនុផលព្រៃឈើ<br>• ឧបសគ្គផ្សេងៗដើម្បីធ្វើពាណិជ្ជកម្មផល និងអនុផលព្រៃឈើ រួមមានការចំណាយដោយប្រយោល | | |



RECOFTC

THE CENTER FOR
PEOPLE AND FORESTS

បេសកកម្មៈ លើកកម្ពស់សមត្ថភាពប្រជាជនមូលដ្ឋានដើម្បីពង្រឹងសិទ្ធិ អភិបាលកិច្ច និងការទទួលបានផលប្រយោជន៍សមស្រប ពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

រីខូហ្វមានតួនាទីសំខាន់នៅក្នុងវិស័យព្រៃឈើ។ រីខូហ្វជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញតែមួយគត់ដែល មានជំនាញក្នុងការអភិវឌ្ឍសមត្ថភាព សម្រាប់សហគមន៍ព្រៃឈើ។ រូខូហ្វធ្វើការងាររបស់ខ្លួនតាមរយៈយុទ្ធសាស្រ្តភ្ជាប់បណ្តាញការងារ និងការកសាងភាពជាដៃគូជាមួយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ប្រជាជនមូល ដ្ឋាន និងគ្រឹះស្ថានអប់រំ និងស្រាវជ្រាវនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់ដទៃទៀត។ រយៈពេលជាង ២៥ ឆ្នាំ នៃបទពិសោធន៍ថ្នាក់អន្តរជាតិរបស់ខ្លួន រីខូហ្វបានរួមចំណែកស្វែងរកដំណោះស្រាយ នូវរាល់បញ្ហារវាងមនុស្ស និង ព្រៃឈើ ប្រកបដោយមានប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាព ដោយរួមមានការសិក្សាស្រាវជ្រាវ និងការវិភាគ ការអនុវត្តសាកល្បងសហគមន៍ព្រៃឈើ និងតាមរយៈការបណ្តុះបណ្តាល។

ការិយាល័យកណ្តាល
ស្ថិតក្នុងសាកលវិទ្យាល័យ Kasetsart University
ប្រអប់សំបុត្រលេខ ១១១
វិថី Phahonyothin ទីក្រុងបាងកក ១០៩០៣ ព្រះរាជាណាចក្រថៃ
ទូរស័ព្ទលេខៈ ៦៦-២-៩៤០-៥៧០០
ទូរសារលេខៈ ៦៦-២-៥៦១-៤៨៨០ ឬ
៦៦-២-៥៦២-០៩៦០
អ៊ីមែលៈ info@recoftc.org

ការិយាល័យក្នុងប្រទេសកម្ពុជា
រដ្ឋបាលព្រៃឈើ អាគារលេខ ៤០
មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ២
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ ០២៣ ៩៩៨ ៦៨៤
អ៊ីម៉ែលៈ cambodia@recoftc.org
គេហទំព័រៈ www.recoftc.org